ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport


វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ របស់ការិយាល័យ អប់រំ យុវជន និងកីឡា៖ ករណីសិក្សានៅក្រុងបាត់ដំបង ខេត្តបាត់ដំបង និង ក្រុងសំរោង ខេត្តឧត្តរមានជ័យ

# EDUCATION STRATEGIC PLAN FORMULATION OF DISTRICT OFFICES OF EDUCATION, YOUTH AND SPORT: CASE IN BATTAMBANG DISTRICT, BATTAMBANG PROVINCE AND SAMRONG DISTRICT, ODDARMEANCHEY PROVINCE


នេត សោភ័ណ្ឌ

NETH SORPHORN


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ របស់ការិយាល័យ អប់រំ យុវជន និងកីឡា៖ ករណីសិក្សានៅក្រុងបាត់ដំបង ខេត្តបាត់ដំបង និង ក្រុងសំរោង ខេត្តឧត្តរមានជ័យ

EDUCATION STRATEGIC PLAN FORMULATION OF DISTRICT OFFICES OF EDUCATION, YOUTH AND SPORT: CASE IN BATTAMBANG DISTRICT, BATTAMBANG PROVINCE AND SAMRONG DISTRICT, ODDARMEANCHEY PROVINCE


**នេត សោភ័ណ្ឌា**

**NETH SORPHORN**


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

**គ្រូណែនាំគោល៖ លោកស្រីបណ្ឌិត មូ ច័ន្ទគុលិកា**

**គ្រូណែនាំរង៖ ឯកឧត្តមបណ្ឌិត សិត សេង**

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា »**ការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំរបស់ការិយាល័យអប់រំ យុវជន និងកីឡា៖ ករណីសិក្សានៅក្រុងបាត់ដំបង ខេត្តបាត់ដំបង និងក្រុងសំរោង ខេត្តឧត្តរមានជ័យ**) «សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទ/នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាត្រូវបានស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខា**

**នេត សោភ័ណ្ឌ**

# លិខិតបញ្ជាក់

**លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា** ជាគ្រូណែនាំគោល

**ឯកឧត្តមបណ្ឌិត សិត សេង** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **នេត សោភ័ណ្ឌ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវស្តីពី «**ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ការិយាល័យអប់រំ យុវជន និងកីឡា** (**ករណីសិក្សានៅក្រុងបាត់ដំបង និងក្រុងសំរោង**) «ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២២

**គ្រូណែនាំគោល** **គ្រូណែនាំរង**

...................................... ....................................

**លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា**
ប្រធាននាយកដ្ឋានគោលនយោបាយ

**ឯកឧត្តមបណ្ឌិត សិត សេង**
នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

# លិខិតឧទ្ទេសនាមគណៈកម្មការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ:..៣៤២៦..អយក.ខ្ទក

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោកបណ្ឌិត | ឡាយ សុវិជ្ជា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៥-លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | លី គីមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៨-លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៩-លោកបណ្ឌិត | អ៊ុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | កាង ស៊ីងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ចាន់ វ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | មឿន លិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោក | ប៉ូ ប៊ុន្នួន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | សឿ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០.លោក | ថាច់ សន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១.លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២.លោកស្រី | សេង សច្ចា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣.លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤.លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥.លោកស្រី | ឯម សុភាលក្ស្មី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣៧០២៤ អយក.ខទន

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

យោងៈ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំៈ

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម | យក់ ង៉ុយ | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម | លាង សេងហាក់ | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម | ម៉ក់ ង៉យ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អ៊ែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្ដីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទគោរពសូមថ្លែងអំណរគុណដល់វិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានបង្កើតកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ សម្រាប់បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ឱ្យមានឱកាសបន្តការសិក្សា ដើម្បីលើកកម្ពស់គុណវុឌ្ឍិមួយកម្រិតបន្ថែមទៀត ក៏ដូចជាផ្តល់ឱកាសដល់រូបខ្ញុំបាទ បានចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការរួមចំណែកជួយដល់ការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឱ្យមានគុណភាព។

ខ្ញុំបាទសូមរំលឹកគុណចំពោះលោកអ្នកមានគុណទាំងពីរ លោកឪពុកនិងអ្នកម្តាយ និងភរិយា ព្រមទាំងបងប្អូនទាំងអស់ ដែលបានផ្តល់ជាកម្លាំងចិត្ត ពេលវេលា ថវិកា និងការគាំទ្រនានាដល់រូបខ្ញុំគ្រប់ពេលវេលា ជាពិសេសក្នុងការសិក្សារៀនសូត្រក្រេបយកចំណេះដឹង ដើម្បីជួយដល់គ្រួសារ និងសង្គមជាតិ។ ជាការពិតណាស់ ការជួយឧបត្ថម្ភគាំទ្រ និងការលះបង់ដ៏ធំធេងរបស់អ្នកទាំងអស់គ្នា ពិតជាមានតម្លៃមិនអាចកាត់ថ្លៃបាន ក្នុងការជំរុញឱ្យខ្ញុំខិតខំប្រឹងប្រែងសិក្សារហូតទទួលបានជោគជ័យ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងខិតខំបង្ហាត់បង្រៀននិងពន្យល់មេរៀនយ៉ាងច្បាស់លាស់ដល់រូបខ្ញុំ ដោយមិនគិតពីការនឿយហត់។ ជាមួយគ្នានេះដែរ ខ្ញុំសូមគោរពអរគុណចំពោះគ្រូណែនាំគោល **លោកស្រីបណ្ឌិត មូ ច័ន្ទគុលិកា** និងគ្រូណែនាំរង **ឯកឧត្តមបណ្ឌិត សិត សេខ** ដែលបានចំណាយពេលវេលាដ៏មមាញឹក ណែនាំនិងពន្យល់ពីការសរសេរនិក្ខេបបទតាំងពីដើមរហូតដល់ចប់ប្រកបដោយជោគជ័យ។

ខ្ញុំសូមអរគុណដល់មិត្តរួមក្រុម និងមិត្តរួមជំនាន់ទាំងអស់ដែលបានគោរពស្រឡាញ់រាប់អាន និងបានរួមសុខទុក្ខជាមួយគ្នាទាំងក្នុងការសិក្សា និងក្រៅការសិក្សានាពេលកន្លងមក។ ពេលវេលាដ៏ពិសេសនេះបានដក់ជាប់នៅក្នុងចិត្តរបស់ខ្ញុំជារៀងរហូត។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ និងញាតិមិត្តទាំងអស់ សូមឱ្យមានសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន និងសម្រេចជោគជ័យគ្រប់ភារកិច្ចទាំងអស់ ព្រមទាំងទទួលបាននូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ប្រព័ន្ធអប់រំនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៩។ នៅឆ្នាំ២០០០ ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០១-២០០៥ ជាលើកដំបូង ក្នុងគោលបំណងពង្រឹងគុណភាពនៃការអប់រំ និងការគ្រប់គ្រងអប់រំ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។។ ក្រោយមក នៅឆ្នាំ២០១៤ ក្រសួងបានជំរុញឱ្យមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៥-២០១៧ ដើម្បីឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨ របស់ក្រសួង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤-២០១៨ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ បន្ទាប់មក នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដើម្បីធានាបាននូវប្រព័ន្ធផែនការអប់រំមានសង្គតិភាពរវាងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត។ ទោះយ៉ាងណា ការរៀបចំផែនការនេះពុំទទួលបានជោគជ័យដូចការរំពឹងទុកនោះទេ ដោយនៅមានបញ្ហាប្រឈមជាច្រើន ដូចជា សមត្ថភាពរបស់អ្នកទទួលបន្ទុករៀបចំផែនការនៅមានកម្រិត ចំណេះដឹងនិងជំនាញក្នុងការវិភាគអំពីវិស័យអប់រំ និងសមត្ថភាពក្នុងការសម្របសម្រួលក្រុម។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណង៣៖ ១) ពិនិត្យមើលដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា ២) សិក្សាពីសមត្ថភាពក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា និង៣) ស្វែងយល់ពីបញ្ហាប្រឈមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា។

តាមរយៈការស្រាវជ្រាវ បង្ហាញថា ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡារបស់ក្រុងបាត់ដំបង និងក្រុងសំរោង នៅមានបញ្ហាប្រឈមជាច្រើន កង្វះចំណេះដឹងលើដំណើរការរៀបចំផែនការ សមត្ថភាពមន្ត្រីរៀបចំផែនការនៅពុំទាន់គ្រប់គ្រាន់ ខ្វះសមត្ថភាពក្នុងការវិភាគស្ថានភាពអប់រំ សមត្ថភាពក្នុងការសម្របសម្រួលនៅពុំទាន់បានល្អ ការគ្រប់គ្រងទិន្នន័យអប់រំនៅពុំទាន់ល្អ និងខ្វះការចូលរួមពីអ្នកពាក់ព័ន្ធ ។

# មាតិកា


**សេចក្តីអះអាងរបស់បេក្ខជន** ..... iii

**លិខិតបញ្ជាក់** ..... iv

**លិខិតឧទ្ទេសនាមគណៈកម្មការការពារនិក្ខេបបទ** ..... v

**លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគ** ..... vii

**សេចក្តីថ្លែងអំណរគុណ** ..... ix

**មូលន័យសង្ខេប** ..... x

**ជំពូកទី១៖ សេចក្តីផ្តើម** ..... 1

១ ១.លំនាំបញ្ហានៃការស្រាវជ្រាវ ..... 1

១ចំណោទបញ្ហានៃការស្រាវជ្រាវ ២. ..... 3

១គោលបំណងនៃការស្រាវជ្រាវ ៣. ..... 4

១.៤ សំណួរសិក្សាស្រាវជ្រាវ ..... 4

១សារៈសំខាន់នៃការស្រាវជ្រាវ ៥. ..... 4

១វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ ៦. ..... 5

១រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ៧. ..... 5

**ជំពូកទី២៖ រំលឹកទ្រឹស្តី** ..... 7

២សេចក្តីផ្តើម ១. ..... 7

២ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២. ..... 9

២កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ៣. ..... 11

២ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៤. ..... 12

២ការអភិវឌ្ឍសមត្ថភាពក្នុងការរៀបចំ និងគ្រប់គ្រងផែនការអប់រំ ៥. ..... 13

**ជំពូកទី៣៖ វិធីសាស្ត្រនៃការស្រាវជ្រាវ** ..... 15

៣គម្រោងស្រាវជ្រាវ ១. ..... 15

៣ការប្រមូលទិន្នន័យ ២. ..... 16

៣ឧបករណ៍ស្រាវជ្រាវ ៣. ..... 17

៣ការជ ៤.្រើសរើសសំណាក ..... 17

៣ការវិភាគទិន្នន័យ ៥. ..... 18

**ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវ** ..... 20

៤២០២៣-ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩ ១..... 20
៤២០២៣-ក្របខណ្ឌពេលវេលាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩ ១.១. ..... 20
៤ ២.១.យន្តការក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩២០២៣- ..... 21
៤ការបង្កើតក្រុមការងារទទួលបន្ទុករៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រ ៣.១.ំ២០១៩២០២៣- ..... 23
៤២០២៣-ការរៀបចំក្របខណ្ឌការងារសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩ ៤.១. ..... 25
៤២០២៣-ខ្លឹមសារ ឬទម្រង់នៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩ ៥.១. ..... 26
៤២០២៣-លំដាប់លំដោយអំពីដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩ ៦.១. ..... 28
៤ដំណើរការរៀបចំផែនការអប់រំមុនពេលកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ៧.១ ..... 29
៤ដំណើរការរៀបចំផែនការអប់រំក្នុងពេលកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ៨.១. ..... 30
៤ ២.សមត្ថភាពក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩២០២៣- ..... 33
៤ ១.២.ការបំប៉នសមត្ថភាពផ្នែកបច្ចេកទេសមុនការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩២០២៣- ..... 33
៤ការតម្រង់ទិសលើការរៀបចំផែនការយុទ្ធសាស្ត្រវិ ២.២.ស័យអប់រំ២០១៩២០២៣- ..... 34
៤២០២៣-ការគាំទ្របច្ចេកទេសលើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩ ៣.២. ..... 35
៤-ចំណេះដឹងមូលដ្ឋាន ឬសមត្ថភាពផ្នែកបច្ចេកទេសក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩ ៤.២. ២០២៣ ..... 36
៤២០២៣-បញ្ហាប្រឈមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩ ៣. ..... 38
៤២០២៣-ដំណោះស្រាយ និងមតិយោបល់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩ ៤. ..... 40
៤ដំណោះស្រ ១.៤.ាយនៅក្នុងដំណើរការរៀបចំផែនការអប់រំ ..... 40
៤មតិយោបល់ដើម្បីឱ្យការរៀបចំផែនការអប់រំមានប្រសិទ្ធភាព និងគុណភាព ២.៤. ..... 41
**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ..... 44
៥សេចក្តីសន្និដ្ឋាន ១. ..... 44
៥សំ ២.ណូមពរ ..... 46
៥សំណូមពរសម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ៣. ..... 47
**ឯកសារយោង** ..... 48
**ឧបសម្ព័ន្ធ** ..... 49
**ឧបសម្ព័ន្ធ១៖ សំណួរសម្ភាសន៍** ..... 49
**ឧបសម្ព័ន្ធ២៖ លិខិតអនុញ្ញាតចុះប្រមូលទិន្នន័យ** ..... 70
**ឧបសម្ព័ន្ធ៣៖ លិខិតឧទ្ទេសនាមគ្រូណែនាំគោល និងគ្រូណែនាំរង** ..... 73
**ឧបសម្ព័ន្ធ៤៖ លិខិតបញ្ជាក់ការគណៈកម្មការការពារនិក្ខេបបទបញ្ចប់** ..... 80

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ប្រព័ន្ធអប់រំនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៩ ដោយបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០១-២០០៥ ជាការរៀបចំផែនការដំបូង ក្រោមគំនិតផ្តួចផ្តើមនិងដឹកនាំរៀបចំដោយរដ្ឋមន្ត្រីក្រសួងអប់រំ និងរដ្ឋលេខាធិការ។ នៅក្នុងដំណើរការរៀបចំមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយនៅផ្ទៃក្នុងក្រសួងអប់រំ យុវជន និងកីឡា តាមរយៈក្រុមការងាររៀបចំគោលនយោបាយធំ២៤ បានបន្តពិគ្រោះយោបល់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និងក្រសួងមហាផ្ទៃ ព្រមទាំងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ។ លើសពីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការអប់រំសម្រាប់ទាំងអស់គ្នាសម្រាប់កម្ពុជាពីឆ្នាំ២០០៣-២០១៥ និងបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅថ្នាក់ជាតិជាច្រើនដំណាក់កាល រួមមាន ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០៦-២០១០, ២០០៩-២០១៣, ២០១៤-២០១៨ និង២០១៩-២០២៣ ក្នុងគោលបំណងពង្រឹងគុណភាពនៃការអប់រំ និងការគ្រប់គ្រងអប់រំ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

នៅឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំព្រះរាជក្រឹតស្តីពី គណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ ក្នុងគោលបំណងសម្របសម្រួល និងដឹកនាំការអនុវត្តគោលនយោបាយស្តីពីវិមជ្ឈការនិងវិសហមជ្ឈការ។ នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលក៍បានរៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី១ (ឆ្នាំ២០១០-២០១៩) ដើម្បីផ្ទេរមុខងារទៅឱ្យថ្នាក់មូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្តឱ្យបានទាន់ពេលវេលា និងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈ ឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ និងសង្គម។ ទន្ទឹមនឹងនេះ នៅឆ្នាំ២០១៤ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមន្ទីរអប់រំ យុវជន និងកីឡា រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ ដើម្បីឆ្លើយតបនឹងផែនការ

យុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨ របស់ក្រសួង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤-២០១៨ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល (Onn& Hyojin, 2019)។ បន្ទាប់មកនៅឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានរៀបចំគោលនយោបាយស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងវិស័យអប់រំ ឆ្លើយតបនឹងការដាក់ចេញគោលនយោបាយនេះផងដែរ។

នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានជំរុញឱ្យការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដើម្បីលើកកម្ពស់គុណភាពអប់រំនិងការគ្រប់គ្រងវិស័យអប់រំ និងធានាបាននូវប្រព័ន្ធផែនការអប់រំមានសង្គតិភាពរវាងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ថ្នាក់ជាតិ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ថ្នាក់រាជធានី ខេត្ត ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា (MoEYS, 2020)។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ត្រូវបានរៀបចំឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា ដែលឈរលើគោលការណ៍ គុណភាព សមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ នៅក្នុងផែនការនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់គោលនយោបាយរយៈពេលមធ្យមចំនួនពីរ ១) ធានាឱ្យការអប់រំមាន គុណភាព សមធម៌ បរិយាបន្ន ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ២) ពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់។ ផែនការនេះ រៀបចំឡើងដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ក្នុងគោលដៅបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា និងបង្កើតមូលដ្ឋានដ៏រឹងមាំឆ្ពោះទៅឆ្នាំ២០៣០ ព្រមទាំងឆ្លើយតបនឹងចក្ខុវិស័យអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា និងកម្មវិធីកំណែទម្រង់អាទិភាពនានារបស់រាជរដ្ឋាភិបាល។ ផែនការនេះ មានទម្រង់ជាការគ្រប់គ្រងតាមបែបអនុវិស័យ រួមមាន អនុវិស័យការអប់រំកុមារតូច អនុវិស័យការអប់រំបឋមសិក្សា អនុវិស័យការអប់រំមធ្យមសិក្សានិងការអប់រំបច្ចេកទេស អនុវស័យការអប់រំឧត្តមសិក្សា អនុវិស័យការអប់រំក្រៅប្រព័ន្ធ អនុវិស័យការអភិវឌ្ឍយុវជន និងអនុវិស័យការអប់រំកាយ និងកីឡា ដោយបង្ហាញពីទំនាក់ទំនងច្បាស់លាស់រវាង

វត្ថុបំណងគោលនយោបាយអប់រំ វត្ថុបំណងរបស់អនុវិស័យ យុទ្ធសាស្ត្រ សកម្មភាពគោល និងតម្រូវការធនធាន ព្រមទាំងការពិនិត្យតាមដាននិងវាយតម្លៃ រួមជាមួយនឹងយន្តការផ្តល់ព័តមានត្រឡប់សម្រាប់ធ្វើការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិផងដែរ (MoEYS, 2019)។

ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅថ្នាក់ក្រោមជាតិ ចាប់ពីថ្នាក់មន្ទីរ ថ្នាក់ក្រុង ស្រុក ខណ្ឌ រហូតដល់សាលារៀន។ ផែនការនេះជាឯកសារគោលប្រើសម្រាប់រៀបចំផែនការនានា ដូចជា ផែនការគោលអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ ផែនការយុទ្ធសាស្ត្រថវិកា ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការថវិកាប្រចាំឆ្នាំ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ បានចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ជាលើកដំបូងនៅឆ្នាំ២០២០។ ចំណែកក្របខណ្ឌពេលវេលានៃការរៀបចំមានភាពយឺតយ៉ាវខ្លាំង និងមិនស្របពេលគ្នាជាមួយនឹងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងថ្នាក់ជាតិ។ ជាងនេះទៀត ដំណើរការរៀបចំផែនការនេះ គឺស្ថិតនៅក្នុងបរិបទដែលកម្ពុជាកំពុងដាក់ឱ្យអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការពេញលេញនៅទូទាំងប្រទេស ដែលជាដំណាក់កាលអន្តរកាលនៃការផ្ទេរមុខងារអប់រំឱ្យនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លើសពីនេះទៀត ដំណើរការរៀបចំផែនការនេះ គឺស្ថិតនៅក្នុងស្ថានភាពប្រឈមខ្លាំង ដែលកម្ពុជាកំពុងទទួលរងផលប៉ះពាល់អវិជ្ជមានដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ (DoP, MoEYS, 2020)។ យោងតាមរបាយការណ៍របស់នាយកដ្ឋានផែនការនៃក្រសួងអប់រំយុវជន និងកីឡា បង្ហាញថា ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រឹមតែ ៣២ភាគរយប៉ុណ្ណោះ បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ (DoP, MoEYS, 2020)។ ផ្អែកតាមវឌ្ឍនភាពនេះ បង្ហាញថាលទ្ធផលដែលសម្រេចបាននៅមានកម្រិតទាបនៅឡើយ បើធៀបនឹងចំនួនក្រុង ស្រុក ខណ្ឌ សរុប២០៤ នៅទូទាំងប្រទេស។ ក្នុងន័យនេះ ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា នៅមានបញ្ហាប្រឈមច្រើន ដែលចាំបាច់ត្រូវ

ធ្វើការស្វែងយល់ឱ្យបានស៊ីជម្រៅបន្ថែមទៀត ដើម្បីឱ្យការរៀបចំផែនការនេះមានប្រសិទ្ធភាពនៅក្នុងដំណាក់កាលបន្ទាប់ ទើបជំរុញឱ្យមានការសិក្សាស្រាវជ្រាវលើប្រធានបទស្ដីពី ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ការិយាល័យអប់រំ យុវជន និងកីឡា៖ ករណីសិក្សានៅក្រុងបាត់ដំបង ខេត្តបាត់ដំបង និងក្រុងសំរោង ខេត្តឧត្តរមានជ័យ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

- ពិនិត្យមើលដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា
- សិក្សាពីសមត្ថភាពក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា
- ស្វែងយល់ពីបញ្ហាប្រឈមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា

## ១.៤ សំណួរសិក្សាស្រាវជ្រាវ

- តើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា មានដំណើរការយ៉ាងដូចម្ដេច?
- តើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា ត្រូវមានសមត្ថភាពអ្វីខ្លះ?
- តើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា មានបញ្ហាប្រឈមអ្វីខ្លះ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះនឹងផ្ដល់ជាមេរៀនពិសោធដល់ការិយាល័យអប់រំ យុវជន និងកីឡាដទៃទៀតក្នុងការសិក្សាស្វែងយល់បន្ថែមទៅលើដំណើរការរៀបចំដែលមានប្រសិទ្ធភាព និងផ្ដល់ជាព័ត៌មានត្រឡប់

ដល់មន្ទីរអប់រំ យុវជន និងកីឡា ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធ ឱ្យបានយល់ដឹងអំពីដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ សមត្ថភាពក្នុងការរៀបចំផែនការ បញ្ហាប្រឈម និងដំណោះស្រាយ ដែលកើតមាននៅក្នុងដំណើរការរៀបចំ ដើម្បីកែលម្អការរៀបចំផែនយុទ្ធសាស្ត្រវិស័យអប់រំរបស់ថ្នាក់ក្រុង ស្រុក ខណ្ឌ ឱ្យមានគុណភាព និងប្រសិទ្ធភាព ឆ្លើយតបនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា។

## ១.៦ វិសាលភាពនិងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវផ្តោតលើដំណើរការរៀបចំ សមត្ថភាពក្នុងការរៀបចំ និងបញ្ហាប្រឈមចម្បងៗក្នុងអំឡុងពេលរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា។ ការសិក្សាស្រាវនេះ មិនធ្វើការប្រៀបធៀបពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រុងមួយទៅក្រុងមួយនោះទេ ដោយគ្រាន់តែសិក្សាអំពីគោលគំនិតរួមក្នុងការរៀបចំផែនការ និងធ្វើការផ្ទៀងផ្ទាត់ទស្សនៈដែលរកឃើញនៅកម្រិតក្រុងជាមួយនឹងមន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡា។ ការសិក្សាស្រាវជ្រាវនេះ ជាករណីសិក្សានៅការិយាល័យអប់រំ យុវជន និងកីឡាក្រុងបាត់ដំបង ខេត្តបាត់ដំបង និងក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ការជ្រើសរើសក្រុងទាំងពីរមកធ្វើជាករណីសិក្សា ដោយសារពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះមុខងារអប់រំចំនួន៣ រួមមាន ការអប់រំកុមារតូច ការអប់រំនៅបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ត្រូវបានផ្ទេរឱ្យនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជា៥ជំពូក ដូចខាងក្រោម៖

**ជំពូកទី១៖ សេចក្តីផ្តើម** ផ្តោតលើ លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរសិក្សាស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ

**ជំពូកទី២៖ រំលឹកទ្រឹស្តី** ផ្តោតលើ ការស្វែងរកទ្រឹស្តីផ្សេងៗដែលពាក់ព័ន្ធនឹងប្រធានបទសិក្សាស្រាវជ្រាវ

**ជំពូកទី៣៖ វិធីសាស្រ្តនៃការស្រាវជ្រាវ** ផ្តោតលើ ការប្រមូលទិន្នន័យសំណាក ការកំណត់ទំហំ ដែនកំណត់នៃសំណាក និងឧបករណ៍វិភាគទិន្នន័យ

**ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវ** បង្ហាញពីលទ្ធផលនៃការវិភាគសំណាក តាមរយៈការផ្តល់ចម្លើយរបស់អ្នកចូលរួមឆ្លើយសំណួរ

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** សំយោគលើខ្លឹមសារនៃលទ្ធផលស្រាវជ្រាវ ដើម្បីធ្វើសេចក្តីសន្និដ្ឋានក្នុងការកំណត់វឌ្ឍនភាព បញ្ហាប្រឈម និងសំណូមពរ ដែលឆ្លើយតបទៅនឹងសំណួរសិក្សាស្រាវជ្រាវ សម្រាប់កែលម្អលើការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំសម្រាប់ថ្នាក់ក្រុង ស្រុក ឱ្យបានល្អប្រសើរ។

# ជំពូកទី២៖ រំលឹកទ្រឹស្តី

## ២.១ សេចក្តីផ្តើម

**ផែនការ** ជាការរំពឹងទុកទៅលើស្ថានភាពដែលនឹងកើតមានឡើងនៅពេលអនាគតដោយការគិតទុកជាមុន តាមរយៈការជ្រើសរើសស្ថានភាពដែលនាំឱ្យសម្រេចវត្ថុបំណង និងការប្តេជ្ញាចិត្តទៅលើសកម្មភាពដែលត្រឹមត្រូវចាំបាច់ ដើម្បីសម្រេចវត្ថុបំណងដោយចំណាយថវិកាតិចបំផុត។ មួយវិញទៀត ផែនការ ជាការគិតអំពីអនាគត និងការខិតខំប្រឹងប្រែងគ្រប់គ្រងទៅលើព្រឹត្តការណ៍នាពេលអនាគត ដោយការរៀបចំនិងការគ្រប់គ្រងលើធនធាននានា ដើម្បីសម្រេចវត្ថុបំណងដែលបានកំណត់។ លើសពីនេះ ផែនការជាមធ្យោបាយនៃការរៀបចំសកម្មភាពជាផ្លូវការ ដើម្បីសម្រេចការអភិវឌ្ឍនៅក្នុងសង្គមដែលមានបញ្ហា និងជាអន្តរាគមន៍សម្រាប់សតវត្សរ៍ទី២០។

**ការរៀបចំផែនការអភិវឌ្ឍ** ជាឆ្អឹងខ្នងរបស់រដ្ឋសង្គមនិយម ចាប់តាំងពីការដួលរលំរបបកុម្មុយនីសនៅឆ្នាំ១៩១៧ ដំបូងនៅ សហភាពនៃសាធារណរដ្ឋសង្គមនិយមសូវៀត បន្ទាប់មកនៅ យូហ្គោស្លាវី អាល់បានី ចិន វៀតណាម ឡាវ គុយបា ។ល។ ក្រោយពីសង្គ្រាមលើកលើកទី២ ប្រទេសជាច្រើនដែលមិនមែនជាប្រទេសសង្គមនិយមនៅអឺរ៉ុបខាងលិច (ប្រទេសបារាំង និងប្រទេសហូឡង់) និងប្រទេសអាស៊ី (ជប៉ុន) យល់ថាការរៀបចំផែនការជាឧបករណ៍ដើម្បីស្តារស្ថានភាពឡើងវិញក្រោយសង្គ្រាម និងតម្រង់ទិសលើដំណើរការអភិវឌ្ឍប្រទេស។ ផ្ទុយទៅវិញ ការរៀបចំផែនការរបស់ប្រទេសសង្គមនិយម លើកឡើងថាការរៀបចំផែនការជាការទទួលយកនូវសារៈសំខាន់នៃ សេដ្ឋកិច្ចទីផ្សារ ក្នុងគោលបំណងគ្រប់គ្រងការវិនិយោគឆ្ពោះទៅសម្រេចគោលដៅអាទិភាពរបស់ប្រទេស ជៀសវាងការធ្វើកិច្ចការដដែលៗ ដើម្បីកាត់បន្ថយអស្ថិរភាពដែលកើតមានឡើង (IIEP, UNESCO, 2010)។

**ផែនការអប់រំ** ត្រូវបានជំរុញដោយអ្នកសេដ្ឋកិច្ចនៅទសវត្សរ៍ឆ្នាំ១៩៥០ និងឆ្នាំ១៩៦០ អ្នកសេដ្ឋកិច្ចឈានមុខ បានផ្សារភ្ជាប់សេដ្ឋកិច្ចទៅនឹងការផ្លាស់ប្តូរ ដែលជាកត្តារួមចំណែកក្នុងផលិតកម្ម (ដើមទុន និងពលកម្ម)។ ទោះយ៉ាងណា ការកើនឡើងនៃកត្តាទាំងនោះ មិនអាចបកស្រាយលម្អិតលើការកើនឡើងនៃ

លទ្ធផលបានទេ។ ទ្រឹស្តីមួយបានលើកឡើងថា ផលិតកម្មក្នុងមួយឯកតាដែលហៅថាផលិតភាព កើនឡើងដោយសារដំណើរការបច្ចេកទេស (Solow, 1956)។ ការសន្និដ្ឋានភាគច្រើនលើកឡើងថា ការអប់រំមានទំនាក់ទំនងខ្លាំងទៅនឹងកំណើនសេដ្ឋកិច្ច (Denison 1962, Schutlz 1961)។ លទ្ធផលដែលរកឃើញនេះពាក់ព័ន្ធនឹងទ្រឹស្តីមួយចំនួនដែលលើកឡើងពីតួនាទីការអប់រំនៅក្នុងការអភិវឌ្ឍប្រទេស។ ទ្រឹស្តីសំខាន់មួយទៀតបានលើកឡើងនៅក្នុងទស្សវត្សរ៍ឆ្នាំ១៩៦០ គឺទ្រឹស្តីមូលធនមនុស្ស ដែលផ្តោតលើការគិតគូរអំពីសង្គមនិងនយោបាយ បង្ហាញថាការវិនិយោគលើការអប់រំមានសារៈសំខាន់ ចាប់ពីទស្សវត្សរ៍ឆ្នាំ១៩៥០ នៅក្នុងអភិវឌ្ឍប្រទេស និងប្រទេសកំពុងអភិវឌ្ឍ។ តួយ៉ាងដូចជា វិបត្តិសេដ្ឋកិច្ចនៅទស្សវត្សរ៍ឆ្នាំ១៩៧០ និង ១៩៨០ នាំឱ្យមានកំណើនភាពមិនមានការងារធ្វើ ភាពក្រីក្រ និងគម្លាតប្រាក់ចំណូលរវាងប្រទេស និងនៅក្នុងប្រទេស ដែលនាំឱ្យមានមន្ទិលទៅលើការសម្មត់ថាការអប់រំពិតជាជំរុញដល់កំណើនសេដ្ឋកិច្ច។ ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងការចំណាយច្រើនលើការអប់រំ និងកំណើនសេដ្ឋកិច្ច បានឆ្លុះបញ្ចាំងតាមរយៈប្រទេសអ្នកមានដែលបានចំណាយថវិកាច្រើនវិនិយោគលើការអប់រំ។

**ផែនការយុទ្ធសាស្ត្រ** មានប្រភពចេញពីសង្គ្រាម ចំណែកពាក្យយុទ្ធសាស្ត្រ មានប្រភពដើមពីភាសាក្រិច ផែនការនេះត្រូវបានរៀបចំឡើងនៅថ្នាក់លើ ដើម្បីសម្រេចគោលដៅរយៈពេលវែងក្នុងការទទួលបានជ័យជំនះនៅក្នុងសង្គ្រាម តាមរយៈ ការប្រយុទ្ធ ការចរចា ឬការប្រើប្រាស់មធ្យោបាយណាមួយទៅតាមស្ថានភាពជាក់ស្តែង។ នៅទស្សវត្សរ៍ ១៩៦០ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានប្រើប្រាស់នៅក្នុងវិស័យពាណិជ្ជកម្ម សម្រាប់ជាឧបករណ៍ក្នុងការគ្រប់គ្រងដែលមានលក្ខណៈស្តង់ដា។ នៅចុងទសវត្សរ៍ ១៩៧០ ផែនការនេះបានយកមកប្រើប្រាស់នៅក្នុងវិស័យអប់រំ ជាពិសេស នៅតាមសកលវិទ្យាល័យ ឬមហាវិទ្យាល័យ។ នៅពាក់កណ្តាលទស្សវត្សរ៍ ១៩៨០ ក្រុង ស្រុក បានរៀបចំនិងផ្សព្វផ្សាយយ៉ាងទូលំទូលាយ ក្រោយមកផែនការនេះត្រូវបានណែនាំឱ្យរៀបចំនៅកម្រិតសាលារៀននៅតាមប្រទេសជាច្រើន (IIEP, UNESCO, 2010)។

## ២.២ ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ

ការរៀបចំផែនការយុទ្ធសាស្ត្រ ជាការចាប់ផ្តើមរៀនសូត្ររួមគ្នា ទទួលបាននូវបច្ចេកទេសថ្មី និងវិធីសាស្ត្រនៃការរៀបចំ មានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ និងរបៀបចូលរួមរៀបចំផែនការ ដោយផ្តល់ភាពជាម្ចាស់ក្នុងការកំណត់ចក្ខុវិស័យ បេសកកម្ម យុទ្ធសាស្ត្រ កម្មវិធីនិងសកម្មភាព និងកំណត់ធនធានសម្រាប់ការអនុវត្តផែនការ (Simon, Isabeau & Marion, 2016)។ វដ្តនៃដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំមានសមាសធាតុសំខាន់ៗដូចជា៖ ទី១ ការវិភាគវិស័យអប់រំ ទី២ ការកំណត់គោលនយោបាយអាទិភាពនិងយុទ្ធសាស្ត្រ ទី៣ ការរៀបចំកម្មវិធី ទី៤ ការកំណត់តម្រូវការហិរញ្ញវត្ថុ ទី៥ ការរៀបចំផែនការសកម្មភាព ទី៦ ការអនុវត្តផែនការ និងទី៧ ការពិនិត្យតាមដាននិងវាយតម្លៃ (IIEP, UNESCO, 2015)។ ការរៀបចំផែនការគួរអនុវត្តទៅតាមជំហាន ឬដំណាក់កាលនីមួយៗនៃការរៀបចំផែនការដែលបានទទួលស្គាល់ និងកំពុងអនុវត្តនៅតាមបណ្តាប្រទេសជាច្រើននៅលើសកលលោក។ ជាទូទៅ ការរៀបចំផែនការត្រូវបានរៀបចំទៅតាម៤ដំណាក់កាល ទី១ ការវិភាគស្ថានភាព ទី២ ការរៀបចំផែនការ ទី៣ ការអនុវត្តផែនការ និងទី៤ ការពិនិត្យតាមដាននិងវាយតម្លៃ។ ចំណែកការរៀបចំផែនការយុទ្ធសាស្ត្រ មាន៣ដំណាក់កាល ទី១ ការវិភាគប្រព័ន្ធ ទី២ ការបង្កើតគោលនយោបាយ និងទី៣ ការរៀបចំផែនការសកម្មភាព។ ការវិភាគប្រព័ន្ធ ផ្តោតលើការប្រមូលទិន្នន័យ វិភាគមុខងារប្រព័ន្ធអប់រំ និងពិនិត្យលើបរិបទផ្សេងៗ ការបង្កើតគោលនយោបាយ ផ្តោតលើការកំណត់គោលដៅរយៈពេលវែង ការរៀបចំផែនការសកម្មភាព ផ្តោតលើការប្រែក្លាយគោលនយោបាយទៅជាការអនុវត្តសកម្មភាព និងការទទួលខុសត្រូវ។ ក្នុងន័យនេះ ការរៀបចំផែនការសកម្មភាព រួមមាន គោលបំណង លទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ ការទទួលខុសត្រូវ និងក្របខណ្ឌពេលវេលាច្បាស់លាស់ (CHHANG, 2008)។

ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំមាន៤ដំណាក់កាល៖ ទី១ ការធ្វើហេតុវិនិច្ឆ័យវិស័យអប់រំ ផ្តោតលើការវិភាគទៅលើស្ថានភាពអប់រំ ដើម្បីរកឱ្យឃើញបញ្ហាប្រឈម និងវឌ្ឍនភាពការងារដែលសម្រេចបាន ព្រមទាំងកំណត់អាទិភាពបញ្ហាប្រឈមដែលត្រូវដោះស្រាយ ទី២ បង្កើតគោលនយោបាយផ្តោតលើការកំណត់គោលដៅរយៈពេលវែង ដែលអាចលើសពីផែនការរយៈពេលមធ្យម និងជ្រើសរើស

យុទ្ធសាស្ត្រដែលសំខាន់ ដើម្បីសម្រេចគោលដៅ ទី៣ ការរៀបចំផែនការ សំដៅលើការរៀបចំផែនការរយៈពេលមធ្យម ដោយផ្តោតលើ៣ចំណុចសំខាន់ៗ រួមមាន ទី១ ការប្រែក្លាយគោលដៅនៃគោលនយោបាយរយៈពេលវែងឱ្យទៅជាវត្ថុបំណង និងចំណុចដៅជាក់លាក់អាចវាស់វែងបានដើម្បីសម្រេចឱ្យបានក្នុងរយៈពេលជាក់លាក់មួយ ទី២ ការរៀបចំកម្មវិធីនិងសកម្មភាពជាអាទិភាព ដើម្បីសម្រេចវត្ថុបំណង ទី៣ ការប៉ាន់ស្មានធនធាន (មនុស្ស ថវិកា និងសម្ភារៈ) ដែលចាំបាច់ដើម្បីអនុវត្តផែនការ ទី៤ ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ជាការរៀបចំផែនការការងារជាក់ស្តែង លើកឡើងពីសកម្មភាពលម្អិតដែលត្រូវអនុវត្តក្នុងមួយឆ្នាំ ដើម្បីសម្រេចគោលដៅ និងវត្ថុបំណងនៅក្នុងផែនការរយៈពេលមធ្យម ដោយបង្ហាញពីការកំណត់ចំណុចដៅច្បាស់លាស់ សកម្មភាពជាក់លាក់ ការទទួលខុសត្រូវ និងក្របខណ្ឌពេលវេលា ទី៤ ការពិនិត្យតាមដាន សំដៅលើការគ្រប់គ្រងលើដំណើរការអនុវត្ត ដែលប្រមូលផ្តុំនូវព័ត៌មាន និងមានលក្ខណៈវិភាគ ដើម្បីរកឱ្យឃើញភាពខ្លាំងនិងភាពខ្សោយ និងដោះស្រាយបញ្ហាដែលកើតមានឡើង តាមការចាំចាច់ដើម្បីសម្រេចលទ្ធផលតាមផែនការ (IIEP, UNESCO, 2010)។ ដើម្បីឱ្យមានគណនេយ្យភាពលើការប្រើប្រាស់ធនធាន និងការអនុវត្តផែនការ ត្រូវមានប្រព័ន្ធពិនិត្យតាមនិងវាយតម្លៃប្រចាំថ្ងៃ ឬប្រចាំខែ សម្រាប់ជាការឆ្លុះបញ្ចាំង វិភាគ និងពិនិត្យលើវឌ្ឍនភាពនិងបញ្ហាប្រឈម ដើម្បីតម្រង់ទិស និងកែលម្អលើការងារដែលកំពុងអនុវត្ត និងការពិនិត្យតាមដានប្រចាំឆ្នាំ ឬ៣ឆ្នាំម្តង ដែលអាចឱ្យយើងដឹងអំពីប្រសិទ្ធភាព និងការប្រែប្រួល ដើម្បីជាមេរៀនពិសោធន៍សម្រាប់រៀបចំផែនការនៅពេលអនាគត (CHHANG, 2008)។

ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡារបស់កម្ពុជា មានដូចតទៅ ទី១ បង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទី២ ពិនិត្យ និងពិភាក្សាកំណត់គោលនយោបាយអាទិភាព និងសូចនាករផលសម្រេច ទី៣ កំណត់ចក្ខុវិស័យ និងវត្ថុបំណងគោលនយោបាយអប់រំ ទី៤ រៀបចំផែនការ និងកិច្ចប្រជុំតាមអនុវិស័យ ឬតាមផ្នែកនីមួយៗ ទី៥ រៀបចំតម្រូវការថវិកាសម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ទី៦ រៀបចំសេចក្តីព្រាងលើកទី១ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ទី៧ ពិគ្រោះយោបល់ជាមួយការិយាល័យជំនាញ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន

ទី៨ រៀបចំសេចក្តីព្រាងលើកទី២ និងលើកចុងក្រោយនៃផែនការយុទ្ធសាស្រ្តវិស័យអប់រំ និងទី៩ អនុម័តជាផ្លូវការដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ (DoP, MoEYS, 2020)។

យោងតាមសេចក្តីណែនាំស្តីពី ការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ២០១៩-២០២៣ សម្រាប់ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា ទម្រង់នៃការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ២០១៩-២០២៣ មាន៦ជំពូក ដូចជា ជំពូកទី១ សេចក្តីផ្តើមនិងការវិភាគការបំពេញការងារ ជំពូកទី២ អាទិភាពនៃការអភិវឌ្ឍរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគោលនយោបាយអប់រំ២០១៩-២០២៣ និងចក្ខុវិស័យឆ្នាំ២០៣០ស្តីពីការអប់រំនៅកម្ពុជា ជំពូកទី៣ ផែនការតាមអនុវិស័យ២០១៩-២០២៣ ជំពូកទី៤ ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជំពូកទី៥ ផែនការហិរញ្ញប្បទាន២០១៩-២០២៣ ជំពូកទី៦ ការពិនិត្យតាមដាននិងវាយតម្លៃផែនការយុទ្ធសាស្រ្តវិស័យអប់រំ២០១៩-២០២៣របស់ថ្នាក់ក្រុង ស្រុក ខណ្ឌ (MOEYS, 2020)។

## ២.៣ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឬហៅថា កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកំណែទម្រង់អភិបាលកិច្ចដ៏មានសារៈសំខាន់មួយរបស់រាជរដ្ឋាភិបាល ដែលបានកំណត់ក្នុងគោលនយោបាយជាតិ និងយុទ្ធសាស្រ្តចតុកោណតាមដំណាក់កាលនីមួយៗជាបន្តបន្ទាប់។ កំណែទម្រង់នេះផ្តោតលើការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិដោយឈរលើគោលការណ៍គន្លឹះនានានៃអភិបាលកិច្ចល្អ គឺភាពជាតំណាង ការចូលរួម ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព នីតិរដ្ឋ បរិយាបន្ន និងសមធម៌សង្គម។ គោលបំណងនៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺបង្កើតនូវវប្បធម៌ប្រជាធិបតេយ្យនៅមូលដ្ឋាន ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន លើកស្ទួចគុណភាពជីវិត និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប្រកបដោយបរិយាបន្ន និងសមធម៌សង្គម។ តាមរយៈការអនុវត្តកំណែទម្រង់នេះ សិទ្ធ អំណាច ការទទួលខុសត្រូវ មុខងារ និងធនធានត្រូវបានផ្ទេរជាបណ្តើរៗពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងន័យ បង្វិតការធ្វើសេចក្តីសម្រេចចិត្តលើការផ្តល់សេវាសាធារណៈឱ្យទៅ

កៀកជិតប្រជាពលរដ្ឋ សំដៅធានាការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈចាំបាច់នានាជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរថែមទៀត។ នៅត្រឹមឆ្នាំ២០២០ បានអនុវត្តបញ្ចប់នូវកម្មវិធីជាតិរយៈពេល១០ឆ្នាំ ដំណាក់កាលទី១ (ឆ្នាំ២០១០-២០២០) ដោយសម្រេចបាននូវសមិទ្ធផលធំៗពាក់ព័ន្ធនឹងការរៀបចំដាក់ឱ្យដំណើរការស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ គោលបំណងនៃការជំរុញការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត រាជរដ្ឋាភិបាលបានសម្រេចរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ រយៈពេល១០ឆ្នាំបន្ថែមទៀត គឺចាប់ពីឆ្នាំ២០២១-២០៣០ សំដៅបន្តពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានសក្តានុពលក្នុងការចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលគឺ ការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ (NP2-SNDD, 2021)។

## ២.៤ ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៩-២០២៣ ត្រូវបានរៀបចំឡើងសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយបានកំណត់អាទិភាពសូចនាករនានា និងមានក្របខណ្ឌពេលវេលាច្បាស់លាស់សម្រាប់អនុវត្ត និងបានកំណត់យន្តការសម្រាប់ការពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើក្របខណ្ឌលទ្ធផល ជាពិសេស កំណត់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទៅតាមមុំនីមួយៗ ដើម្បីបន្តទទួលបានផលចំណេញខ្ពស់លើការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងឈានឡើងពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប បន្តឆ្ពោះទៅសម្រេចឱ្យបានជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងរួមចំណែកសម្រេចឱ្យបានក្របខណ្ឌគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ត្រូវបានរៀបចំឡើងជា៧ជំពូក។ នៅក្នុងជំពូកទី១ បង្ហាញពី ប្រវត្តិដើម ការពិនិត្យឡើងវិញលើផែនការអភិវឌ្ឍន៍កម្ពុជា និងយុទ្ធសាសាស្ត្រចតុកោណដំណាក់ដាក់កាលទី៤ ជំពូកទី២ បង្ហាញដោយសង្ខេបពីសមិទ្ធផលសំខាន់ៗ និងបញ្ហាប្រឈម នៅក្នុងអំឡុងពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ជំពូកទី៣ បង្ហាញពីក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច

សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ ជំពូកទី៤ បង្ហាញពី គោលនយោបាយនិងសកម្មភាពអាទិភាព២០១៩-២០២៣ ដែលក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្ត ជំពូកទី៥ បង្ហាញការប៉ាន់ស្មានតម្លៃដែលរួមទាំងចំណាយ ប្រភពធនធាន និងការកំណត់កម្មវិធីចំណាយ ជំពូកទី៦ បង្ហាញពីក្របខណ្ឌលទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ឆ្នាំ២០១៩-២០២៣ ជំពូកទី៧ បង្ហាញពីសេចក្តីសន្និដ្ឋាន (NSDP, 2019)។

## ២.៥ ការអភិវឌ្ឍសមត្ថភាពក្នុងការរៀបចំ និងគ្រប់គ្រងផែនការអប់រំ

ការអភិវឌ្ឍសមត្ថភាពបានក្លាយជាទស្សនៈដ៏ពេញនិយមក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ពាក្យបច្ចេកទេសដែលប្រើប្រាស់ពីមុនគឺ ការកសាងសមត្ថភាព ក្រោយមកពាក្យនេះត្រូវបានផ្លាស់ប្តូរទៅជាពាក្យ ការអភិវឌ្ឍសមត្ថភាព។ នៅទស្សវត្ស ១៩៦០ និង ១៩៧០ ការអភិវឌ្ឍសមត្ថភាពផ្តោតលើកម្រិតបុគ្គល ហេតុដល់ចុងទស្សវត្សរ៍១៩៧០ ត្រូវបានគេមើលឃើញថា នផលប៉ះពាល់តិចតួចលើសមត្ថភាពរបស់អង្គភាព ក្រោយមក នៅទស្សវត្សរ៍ ១៩៨០ ការអភិវឌ្ឍសមត្ថភាពត្រូវបានផ្តោតលើកម្រិតអង្គភាព (De Grauwe, 2009, p. 40)។ ការអភិវឌ្ឍសមត្ថភាព ផ្តោតលើ ការលើកកម្ពស់សមត្ថភាពបំពេញការងាររបស់បុគ្គល អង្គភាព ការគ្រប់គ្រងរដ្ឋបាល និងកែលម្អបរិបទសង្គម សេដ្ឋកិច្ច និងនយោបាយ (De Grauwe, 2009, p. 43)។ ផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ ២០២០-២០២៤ បានកំណត់ផ្នែកសំខាន់ៗនៃការអភិវឌ្ឍសមត្ថភាពនៅកម្រិតស្ថាប័ន អង្គភាព និងបុគ្គល។ ទី១ ការអភិវឌ្ឍសមត្ថភាពកម្រិតស្ថាប័ន រដ្ឋបាលសាធារណៈមានទំនួលខុសត្រូវទៅលើគោលនយោបាយនិងយុទ្ធសាស្ត្រ ការបែងចែកភារកិច្ចនិងស្វ័យភាព និងការគ្រប់គ្រងទូទៅលើបុគ្គលិក។ បញ្ហាសមត្ថភាពនៅកម្រិតស្ថាប័នរួមមាន៖ របៀបគ្រប់គ្រងបុគ្គលិករដ្ឋបាលសាធារណៈ ការបែងចែកទំនួលខុសត្រូវនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងភ្នាក់ងារផ្សេងៗទៀត ដូចជាវិស័យឯកជននិងដៃគូអភិវឌ្ឍន៍ និងតួនាទីក្នុងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្របខណ្ឌគតិយុត្ត និងគោលនយោបាយនិងផែនការអប់រំ ទី២ ការអភិវឌ្ឍសមត្ថភាពកម្រិតអង្គភាព រចនាសម្ព័ន្ធនិងបរិយាកាសអំណោយផល ការគ្រប់គ្រងផ្ទៃក្នុង ធនធាន និងគណនេយ្យភាពចាំបាច់ត្រូវឆ្លើយតបទៅនឹងអាណត្តិ និង

ភារកិច្ចដែលបានកំណត់សម្រាប់អង្គភាព (សាលារៀន គ្រឹះស្ថានបណ្ដុះបណ្ដាល គ្រឹះស្ថានឧត្ដមសិក្សា នាយកដ្ឋាន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ល។) ។ បញ្ហាសមត្ថភាពនៅកម្រិតអង្គភាពរួមមានៈ រចនាសម្ព័នរបស់អង្គភាព និងភាពឆ្លើយតបទៅនឹងអាណត្តិរបស់អង្គភាព ការគ្រប់គ្រងចាត់ចែង (ការប្រាស្រ័យទាក់ទង និងការសម្របសម្រួល) ស្វ័យភាពក្នុងការសម្រេចចិត្ត ធនធាននិងការវិភាជន៍ថវិកា និងទំនួលខុសត្រូវរបស់អង្គភាព។ ទី៣ ការអភិវឌ្ឍសមត្ថភាពកម្រិតបុគ្គល ភារកិច្ចនិងការទទួលខុសត្រូវដែលបានប្រគល់ឱ្យបុគ្គលម្នាក់ៗត្រូវតែឆ្លើយតបទៅនឹងគុណវុឌ្ឍិ បទពិសោធ ការបណ្ដុះបណ្ដាល និងការផ្ដល់ការលើកទឹកចិត្ត។ បញ្ហាសមត្ថភាពនៅកម្រិតបុគ្គលរួមមានៈ មុខតំណែងមិនត្រូវនឹងប្រវត្តិរូបបុគ្គល សេចក្ដីពណ៌នាមុខតំណែងនិងភាពមិនច្បាស់លាស់ ឱកាសទទួលបានការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ ការលើកទឹកចិត្តចំពោះការបំពេញការងាររបស់បុគ្គល (CDMP, 2020-2024)។

# ជំពូកទី៣៖ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ការិយាល័យអប់រំ យុវជន និងកីឡា (ករណីសិក្សានៅក្រុងបាត់ដំបង និងក្រុងសំរោង) អ្នកស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដើម្បីស្វែងយល់ពីដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ សមត្ថភាពក្នុងការរៀបចំ និងបញ្ហាប្រឈមនៅក្នុងដំណើរការរៀបចំ។ វិធីសាស្ត្រតាមបែបគុណវិស័យ គឺប្រើប្រាស់សំណួរសម្ភាសន៍ (Semi-Structured Interview) ដើម្បីទទួលបានទស្សនៈយល់ឃើញជារួមរបស់អ្នករៀបចំ និងអ្នកពាក់ព័ន្ធ។

## ៣.១ គម្រោងស្រាវជ្រាវ

គម្រោងស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដើម្បីសម្រេចវត្ថុបំណងស្រាវជ្រាវចំនួន៣គឺ៖ ទី១ ពិនិត្យមើលដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ទី២ កំណត់សមត្ថភាពក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា ទី៣ ស្វែងយល់ពីបញ្ហាប្រឈមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា។ អ្នកសិក្សាស្រាវជ្រាវប្រើប្រាស់សំណួរសម្ភាសន៍ ដើម្បីប្រមូលទិន្នន័យពីអ្នកពាក់ព័ន្ធរួមមាន បុគ្គលិកនៅការិយាល័យអប់រំ យុវជន និងកីឡាក្រុងបាត់ដំបង ខេត្តបាត់ដំបង និងក្រុងសំរោង ខេត្តឧត្តរមានជ័យ ថ្នាក់ដឹកនាំការិយាល័យផែនការនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង និងខេត្តឧត្តរមានជ័យ និងថ្នាក់ដឹកនាំនាយកដ្ឋានផែនការនៃក្រសួងអប់រំ យុវជន និងកីឡា។ អ្នកសិក្សាស្រាវជ្រាវបានការពារគម្រោងស្រាវជ្រាវនៅថ្ងៃទី២៧ ដល់ ២៨ ខែមករាឆ្នាំ២០២២ ដោយឆ្លងកាត់ការវាយតម្លៃ និងតម្រិសរបស់គណៈកម្មការ និងទទួលបានការឯកភាពលើប្រធានបទស្រាវជ្រាវពីគ្រូណែនាំគោល និងគ្រូណែនាំរង។ អ្នកសិក្សាស្រាវជ្រាវបានចាប់ផ្តើមចុះប្រមូលទិន្នន័យពីថ្ងៃទី២ ខែឧសភា រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២ ដោយយោងតាមលិខិតលេខ ២៣៤១ អយក.វជអ និងលិខិតឧទ្ទេសនាមលេខ

២៤៦៦ អយក.ឧទន ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ របស់ក្រសួងអប់រំ យុវជន និងកីឡា និងលិខិតអនុញ្ញាតលេខ ០១២/២២ ល.អ.ច/សំរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ របស់រដ្ឋបាលក្រុងសំរោង ខេត្តឧត្តរមានជ័យ និងលិខិតជូនដំណឹងលេខ ១៥១៥ អយកខ. របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង គោរពជូនលោកអភិបាលក្រុងបាត់ដំបង ចុះនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ និងទទួលបានការឯកភាពពីរដ្ឋបាលក្រុងបាត់ដំបង តាមលិខិតលេខ ២៦៨/២២ កបប.បប ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ ព្រមទាំងទទួលបានការអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យពីនាយកដ្ឋានផែនការនៃក្រសួងអប់រំ យុវជន និងកីឡា។

## ៣.២ ការប្រមូលទិន្នន័យ

ក្រោយពីឆ្លងយោបល់គ្រូណែនាំគោល និងគ្រូណែនាំរង ក្នុងការសរសេរជំពូកទី១ ដល់ទី៣ រួចរាល់អ្នកសិក្សាស្រាវជ្រាវបានរៀបចំសំណួរសម្ភាសន៍សម្រាប់ការចុះប្រមូលទិន្នន័យ។ ក្នុងការចុះប្រមូលទិន្នន័យអ្នកសិក្សាស្រាវជ្រាវបានអនុវត្តតាមលិខិតលេខ ២៣៤១ អយក.វជអ និងលិខិតឧទ្ទេសនាមលេខ ២៤៦៦ អយក.ឧទន របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលផ្តល់ដោយវិទ្យាស្ថានជាតិអប់រំ ជម្រាបជូនដំណឹងដល់រដ្ឋបាលក្រុងបាត់ដំបង ខេត្តបាត់ដំបង និងរដ្ឋបាលក្រុងសំរោង ខេត្តឧត្តរមានជ័យ តាមរយៈការជូនដំណឹងថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡានៃខេត្តបាត់ដំបង និងខេត្តឧត្តរមានជ័យ ដើម្បីស្នើសុំការជួយសម្របសម្រួលសុំការអនុញ្ញាតចុះប្រមូលទិន្នន័យ និងជម្រាបជូនពីគោលបំណងនៃការសិក្សាស្រាវជ្រាវ និងជម្រាបជូនដំណឹងទៅនាយកដ្ឋានផែនការនៃក្រសួងអប់រំ យុវជន និងកីឡា ដើម្បីសុំការអនុញ្ញាតជួបសម្ភាសន៍អ្នកទទួលបន្ទុករៀបចំផែនការ ដែលឆ្លើយតបនឹងលិខិតលេខ ២៣៤១ អយក.វជអ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ បានកំណត់ពេលវេលាក្នុងការចុះប្រមូលទិន្នន័យ ចាប់ពីថ្ងៃទី០២ ខែឧសភា រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។

អ្នកស្រាវជ្រាវបានសម្ភាសន៍ផ្ទាល់ជាមួយថ្នាក់ដឹកនាំនាយកដ្ឋានផែនការនៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានការិយាល័យផែនការនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង និងខេត្តឧត្តរមានជ័យ និងបុគ្គលិកអប់រំនៃការិយាល័យអប់រំ យុវជន និងកីឡាក្រុងបាត់ដំបង និងក្រុងសំរោង ដើម្បីជម្រាបជូនអំពី

គោលបំណង និងសារៈប្រយោជន៍នៃការស្រាវជ្រាវ។ បន្ទាប់មក អ្នកស្រាវជ្រាវបានផ្តល់សំណួរសម្ភាសន៍ដល់អ្នកចូលរួម និងធ្វើការសម្ភាសន៍ដោយផ្ទាល់ជាលក្ខណៈបុគ្គល ដោយចំណាយពេល៣០នាទី និងសម្ភាសន៍ជាក្រុម ចំណាយពេលវេលា ១ម៉ោង។ អ្នកស្រាវជ្រាវបាន យកចិត្តទុកដាក់ក្នុងការសម្របសម្រួលក៏ដូចជាសហការជាមួយក្រុមគោលដៅទាំងអស់ ក្នុងគោលបំណងទទួលបានទិន្នន័យច្បាស់លាស់ និងព័ត៌មានដែលអាចជឿទុកចិត្តបានសម្រាប់ការវិភាគក្នុងការសិក្សាស្រាវជ្រាវនេះ។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ដើម្បីឱ្យការប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ អ្នកស្រាវជ្រាវបានរៀបចំសំណួរសម្ភាសន៍៣ប្រភេទ៖ ទី១ សំណួរសម្ភាសន៍សម្រាប់ថ្នាក់ដឹកនាំនាយកដ្ឋានផែនការនៃក្រសួងអប់រំ យុវជន និងកីឡា ទី២ សំណួរសម្ភាសន៍សម្រាប់ប្រធានការិយាល័យផែនការនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ទី៣ សំណួរសម្ភាសន៍សម្រាប់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក។ សំណួរសម្ភាសន៍ទាំងនេះមានលក្ខណៈបើក ដើម្បីទទួលបានទស្សនៈ ឬការយល់ឃើញទូលំទូលាយរបស់អ្នកចូលរួម និងបានបែងចែកជា៥ផ្នែកធំៗ រួមមាន ទី១ ព័ត៌មានទូទៅរបស់អ្នកចូលរួម ទី២ ដំណើរការនិងក្របខណ្ឌក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ទី៣ សមត្ថភាពក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ទី៤ បញ្ហាប្រឈមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ទី៥ ដំណោះស្រាយ ឬមតិយោបល់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣។

## ៣.៤ ការជ្រើសរើសសំណាក

អ្នកសិក្សាស្រាវជ្រាវ បានជ្រើសការិយាល័យអប់រំ យុវជន និងកីឡាក្រុងចំនួន២ គឺក្រុងបាត់ដំបង ខេត្តបាត់ដំបង និងក្រុងសំរោង ខេត្តឧត្តរមានជ័យ និងការិយាល័យផែនការនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងនាយកដ្ឋានផែនការនៃក្រសួងអប់រំ យុវជន និងកីឡា។ ហេតុផលនៃការជ្រើសរើសខេត្តបាត់ដំបងជាករណីសិក្សា ដោយខេត្តនេះត្រូវបានជ្រើសរើសដាក់ឱ្យអនុវត្តសាកល្បងកំណែទម្រង់វិមជ្ឈការ និងវិសហ-

មជ្ឈការមុនគេនៅឆ្នាំ២០១៦ ក្រោយមករាជធានី-ខេត្តទាំងអស់ ត្រូវបានដាក់ឱ្យអនុវត្តពេញលេញនៅឆ្នាំ ២០១៩។ ចំពោះហេតុផលនៃការជ្រើសរើសខេត្តឧត្តរមានជ័យមកធ្វើជាករណីសិក្សា ដោយមូលហេតុ ខេត្តនេះជាខេត្តមួយស្ថិតនៅក្នុងចំណោមខេត្តដែលអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការនៅទូទាំងប្រទេស ហើយចំពោះឧត្តរមានជ័យ ជាខេត្តមួយក្នុងចំណោមខេត្ត៤ (ខេត្តរតនគិរី មណ្ឌលគិរី ប៉ៃលិន ឧត្តរមានជ័យ) ដែលបានខិតខំប្រឹងប្រែងជំរុញឱ្យក្រុងស្រុកទាំងអស់ បានបញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ និងបានផ្ញើឯកសារជាផ្លូវការមកក្រសួង (នាយកដ្ឋានផែនការ, ២០២០)។ សមាសភាព ដែលចូលរួមផ្តល់ព័ត៌មានសរុប១៥នាក់ រួមមាន ថ្នាក់ដឹកនាំនាយកដ្ឋានផែនការនៃក្រសួងអប់រំ យុវជន និង កីឡា ១នាក់ ប្រធានការិយាល័យផែនការនិងគ្រប់គ្រងជំនួយនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ១នាក់ ក្នុង១ខេត្ត បុគ្គលិកអប់រំថ្នាក់ការិយាល័យក្រុង ៦នាក់ ក្នុង១ការិយាល័យ រួមមាន ផ្នែកផែនការ ផ្នែកអប់រំ កុមារតូច ផ្នែកបឋមសិក្សា ផ្នែកមធ្យមសិក្សា ផ្នែកអប់រំក្រៅប្រព័ន្ធ ផ្នែកយុវជន និងកីឡា។

### ៣.៥ ការវិភាគទិន្នន័យ

ក្រោយពីការប្រមូលទិន្នន័យតាមរយៈការសម្ភាសន៍ ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ អ្នកសិក្សាស្រាវជ្រាវបានធ្វើការសំយោគទៅលើទិន្នន័យដែលប្រមូលបានតាមបែបខ្លឹមសារ ដោយកំណត់យកនូវគោលគំនិតរួមសំខាន់ៗ និងបកស្រាយទៅតាមសំណួរសិក្សាស្រាវជ្រាវ។ អ្នកស្រាវជ្រាវ ស្រង់យករាល់គំនិត ឬចម្លើយពីអ្នកចូលរួមនៅកម្រិតក្រុង ស្រុក មន្ទីរ និងក្រសួង ហើយអ្នកស្រាវជ្រាវអាន ដោយលម្អិត អានដោយយកចិត្តទុកដាក់ និងអានជាច្រើនដង ដើម្បីស្រង់យកគំនិតធំៗចេញពីសំណាកទាំង នោះ បន្ទាប់មកអ្នកស្រាវជ្រាវអានដោយលម្អិតទៅលើមូលហេតុ និងផលប៉ះពាល់ ហេតុអ្វីបានជាអ្នកចូល រួមមានគំនិត និងដើមហេតុដែលជះឥទ្ធិពលនៅក្នុងដំណើរការរៀបចំនេះ។ បន្ទាប់មក អ្នកស្រាវជ្រាវ ធ្វើការ ផ្ទៀងផ្ទាត់នូវទស្សនៈ ឬគំនិតយល់ឃើញរបស់អ្នកចូលរួមនៅកម្រិតក្រុង ស្រុក ជាមួយទស្សនៈ ឬគំនិត យល់យល់ឃើញរបស់មន្ទីរ និងក្រសួង។ ក្រោយពីទទួលបានលទ្ធផល និងធ្វើការបកស្រាយ រួចមក អ្នកស្រាវជ្រាវ ធ្វើការសន្និដ្ឋានព្រមទាំងធ្វើការផ្ទៀងផ្ទាត់លទ្ធផលជាមួយនឹងចំណោទបញ្ហាឡើងវិញ ដើម្បី ធ្វើឱ្យប្រាកដថាលទ្ធផលសិក្សាស្រាវជ្រាវពិតជាបានឆ្លើយតបនឹងសំណួរ និងគោលបំណងនៃការស្រាវជ្រាវ

ហើយធ្វើការសន្និដ្ឋាន និងវាយតម្លៃទៅលើដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ នៃរដ្ឋបាលក្រុង ស្រុក។ អ្នកស្រាវជ្រាវនឹងចូលរួមផ្តល់ជាអនុសាសន៍ និងសំណូមពរមួយចំនួនដល់ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមពង្រឹងលើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឱ្យមានគុណភាព។

# ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវ

## ៤.១ ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

### ៤.១.១ ក្របខណ្ឌពេលវេលាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

ផ្អែកតាមលទ្ធផលសិក្សាស្រាវជ្រាវបានរកឃើញថា ក្របខណ្ឌពេលវេលាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ដែលផ្តល់ដោយក្រសួងអប់រំ យុវជន និងកីឡា ហាក់ដូចជាមានភាពយឺតយ៉ាវខ្លាំង នៅមិនទាន់សមស្របនៅឡើយ និងមិនត្រូវទៅតាមដំណាក់កាលនៃដំណើរការរៀបចំផែនការ ដែលត្រូវការពេលវេលារៀបចំមុនមួយឆ្នាំនៃការអនុវត្តផែនការ ពោលគឺត្រូវរៀបចំឱ្យបានរួចរាល់យ៉ាងហោចនៅចុងឆ្នាំ២០១៨។ ដោយឡែកការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរហូតដល់ដើមត្រីមាសទី៣ឆ្នាំ២០២០ឯណោះវិញ។ តាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំភាគច្រើននៅការិយាល័យអប់រំ យុវជន និងកីឡា បានលើកឡើងស្រដៀងគ្នាថា ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ២០២០ មានន័យថា យឺតប្រមាណជា២ឆ្នាំ។ បុគ្គលិកការិយាល័យអប់រំ យុវជន និងកីឡាក្រុងមួយចំនួនបានលើកឡើងថាពួកគាត់ *"...ទទួលបានសេចក្តីជូនដំណឹងមករដ្ឋបាលក្រុងនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០..."* ខ្លះទៀតបាននិយាយថា *"...ចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ នៅខែកក្កដា ឆ្នាំ២០២០..."* និងមួយចំនួនទៀតបានប្រាប់ថា *"...ចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ នៅឆ្នាំ២០២០..."* ដោយពុំច្បាស់ថានៅក្នុងខែណា។ ទាំងនេះអាចបញ្ជាក់បានថា ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅកម្រិតស្រុកនីមួយៗ ពុំបានធ្វើឡើងស្របពេលជាមួយគ្នា ហើយការចាប់ផ្តើមធ្វើផែនការនេះទៀតសោត គឺយឺតពេលបាត់ទៅហើយ ដោយសារក្រសួងអប់រំ យុវជន និងកីឡា ជូនដំណឹងពីការរៀបចំមិនបានទាន់ពេលវេលា។

ភាពយឺតយ៉ាវនៃពេលវេលាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដែលបានរកឃើញនៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្របទៅនឹងការជូនដំណឹងស្តីពីការរៀបចំ

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា ផ្តល់ជូនតាមរយៈមន្ទីរអប់រំ យុវជន និងកីឡា តម្រូវឱ្យការិយាល័យក្រុង ស្រុក រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣របស់ខ្លួន។ តាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅមន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងថា៖

*"...ជូនដំណឹងពីក្រសួងអប់រំ យុវជន និងកីឡាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ សម្រាប់ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡា នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ មន្ទីរអប់រំយុវជន និងកីឡាខេត្ត បានបន្តជម្រាបជូនដំណឹងនេះទៅលោក លោកស្រីអភិបាល នៃគណៈអភិបាលក្រុង ស្រុក..."*

*"...ជូនដំណឹងស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ តាមរយៈមន្ទីរអប់រំ យុវជន នៅខែកក្កដា ឆ្នាំ២០២០..."*

### ៤.១.២ យន្តការក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

តាមរយៈលទ្ធផលស្រាវជ្រាវបានរកឃើញថា ការិយាល័យអប់រំ យុវជន និងកីឡា នៅពុំទាន់យល់ដឹងច្បាស់អំពី យន្តការក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំប្រកបដោយប្រសិទ្ធភាពដែលនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលបញ្ហានេះអាចដោយសារការិយាល័យអប់រំ យុវជន និងកីឡាក្រុងទើបតែចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួនជាលើកដំបូង និងមិនទាន់យល់ដឹងស៊ីជម្រៅទៅលើគោលការណ៍ណែនាំរបស់ក្រសួង ឬមន្ទីរ។ តាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅការិយាល័យអប់រំ យុវជន និងកីឡា បានលើកឡើងផ្សេងៗគ្នាថា៖

*"...ផ្អែកលើចក្ខុវិស័យ និងបេសកកម្ម របស់ការិយាល័យ..."*

*"...ប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ..."*

*"...ប្រមូលទិន្នន័យ បង្កើតគណៈកម្មការ និងរៀបចំសមាសភាពគណៈកម្មការ..."*

*"...បង្កើតគណៈកម្មការ រៀបចំឱ្យមានការចូលរួម និងសហការ..."*

*"...អញ្ជើញអ្នកពាក់ព័ន្ធទាំងអស់ចូលរួម..."*

*"...ប្រជុំផ្សព្វផ្សាយពីការរៀបចំផែនការជាមួយអ្នកពាក់ព័ន្ធ បង្កើតគណៈកម្មការរៀបចំផែនការ ប្រជុំបែងចែកគណៈកម្មការ និងកំណត់តួនាទីច្បាស់លាស់ ប្រជុំរៀបចំផែនការពីគ្រប់អនុវិស័យ និងអ្នកពាក់ព័ន្ធដើម្បីប្រមូលទិន្នន័យ និងប្រឹក្សាយោបល់ពីផែនការ រៀបចំលិខិតអញ្ជើញអ្នកពាក់ព័ន្ធចូលរួមប្រជុំឆ្លងផែនការរួមគ្នាតាមការកំណត់ច្បាស់លាស់ ប្រជុំសម្រេចផែនការយុទ្ធសាស្ត្ររួមគ្នាពីអ្នកពាក់ព័ន្ធ..."*

យន្តការនៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដែលបានរកឃើញនៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡាក្រុង នៅពុំទាន់មានលក្ខណៈច្បាស់លាស់នៅឡើយ ផ្អែកតាមលទ្ធផលដែលបានរកឃើញនៅកម្រិតមន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡា ទៅលើយន្តការនៃការរៀបចំផែនការរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង នៅមានភាពខ្វះចន្លោះច្រើន។ ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង នៅមិនទាន់អាចធានាបាននូវដំណើរការរៀបចំប្រកបដោយប្រសិទ្ធភាពនោះទេ។ តាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅមន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងថា៖

*"...បង្កើតគណៈកម្មការទទួលបន្ទុកការរៀបចំផែនការ រៀបចំសមាសភាព គណៈកម្មការ រៀបចំការប្រមូលទិន្នន័យតាមអនុវិស័យ រៀបចំឱ្យមានការចូលរួម និងសហការល្អ រៀបចំការពិនិត្យតាមដាននិងវាយតម្លៃប្រចាំឆមាស ឬប្រចាំឆ្នាំរួមគ្នាលើការអប់រំ កំណត់កាលបរិច្ឆេទការពិនិត្យ តាមដានលើវឌ្ឍនភាពដែលសម្រេចបាន ប្រជុំឆ្លងនិងសម្រេច..."*

*"...ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព និងគុណភាព ស្នើឱ្យលោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ទី១ បង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រទៅតាមទម្រង់ដែលក្រសួងបានផ្តល់ជូន ទី២ កំណត់តួនាទីនិងភារកិច្ចរបស់ក្រុមការងារឱ្យបានច្បាស់លាស់ ទី៣ រៀបចំផែនការ យុទ្ធសាស្ត្រវិស័យអប់រំតាមលំដាប់លំដោយ និងមានលក្ខណៈបត់បែនតាមការចាំបាច់ មានដូចជា បង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ កំណត់ចក្ខុវិស័យ និងវត្ថុបំណងគោលនយោបាយអប់រំ រៀបចំផែនការ និងប្រជុំតាមអនុវិស័យ ឬតាមផ្នែកនីមួយៗ រៀបចំតម្រូវការថវិកាសម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ*

*រៀបចំសេចក្តីព្រាងលើកទី១នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយពិគ្រោះយោបល់ជាមួយការិយាល័យជំនាញនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន រៀបចំសេចក្តីព្រាងលើកទី២ និងលើក ចុងក្រោយនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងអនុម័តជាផ្លូវការពីអភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ទី៤ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ មានលទ្ធភាពបត់បែននៅក្នុងដំណើរការរៀបចំ..."*

## ៤.១.៣ ការបង្កើតក្រុមការងារទទួលបន្ទុករៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

ពាក់ព័ន្ធនឹងលទ្ធផលស្រាវជ្រាវបានរកឃើញថា ការិយាល័យអប់រំ យុវជន និងកីឡាក្រុង បានយល់ដឹងច្បាស់អំពីគោលបំណង និងសារៈសំខាន់នៃការបង្កើតក្រុមការងារនេះឡើង ដើម្បីគាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឱ្យមានប្រសិទ្ធភាព តាមរយៈការលើកឡើង ដូចជា ការកំណត់សមាសភាពគណៈកម្មការសំខាន់ៗ និងការកំណត់សមាសភាពចូលរួមពីអ្នកពាក់ព័ន្ធ ព្រមទាំងការកំណត់តួនាទីនិងភារកិច្ចរបស់គណៈកម្មការទាំងនោះ។ តាមលទ្ធផលដែលទទួលបានពី ការសម្ភាសន៍បុគ្គលិកអប់រំនៅការិយាល័យអប់រំ យុវជន និងកីឡា បានលើកឡើងថា៖

*"...មានសមាសភាពគណៈកម្មការដឹកនាំ គណៈកម្មការបច្ចេកទេស គណៈកម្មការគាំទ្របច្ចេកទេស ក្រុមលេខាធិការដ្ឋាន..."*

*"...មានសមាសភាពចូលរួមពី លោកអភិបាលក្រុង ប្រធាននិងអនុប្រធានការិយាល័យ មន្ត្រីទទួលបន្ទុកតាមអនុវិស័យ មន្ត្រីផ្នែកផែនការ អង្គការដៃគូ និងអ្នកពាក់ព័ន្ធ..."*

*"...មានសមាសភាពគណៈកម្មការ៤ធំៗ គឺគណៈកម្មការដឹកនាំ គណៈកម្មការបច្ចេកទេស គណៈកម្មការគាំទ្របច្ចេកទេស និងក្រុមលេខាធិការដ្ឋាន..."*

*"...ដឹកនាំគ្រប់គ្រងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ..."*

*"...ធ្វើសេចក្តីសម្រេចលើខ្លឹមសារនៅក្នុងផែនការ រៀបចំពេលវេលា និងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ តម្រង់ទិសការរៀបចំផែនការ រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ..."*

*"...ទី១ គណៈកម្មការដឹកនាំ៖ ធ្វើសេចក្តីសម្រេចចិត្ត ដឹកនាំ គ្រប់គ្រង តម្រង់ទិស និងកៀរគរធនធាន ទី២ គណៈកម្មការបច្ចេកទេស៖ រៀបចំក្របខណ្ឌពេលវេលា និងប្រជុំពិគ្រោះយោបល់រៀបចំសេចក្តីព្រាង ទី៣ គណៈកម្មការគាំទ្របច្ចេកទេស៖ គាំទ្រផ្នែកបច្ចេកទេសលើការរៀបចំផែនការ រៀបចំលិខិតរដ្ឋបាល ទី៤ ក្រុមលេខាធិការដ្ឋាន៖រៀបចំលិខិតរដ្ឋបាលដំណើរការប្រជុំឆ្លងសេចក្តីព្រាង រៀបចំសម្របសម្រួលការប្រជុំ ធ្វើរបាយការណ៍ជូនក្រុមការងារ..."*

ជាមួយគ្នានេះដែរ ការបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដែលបានរកឃើញនៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង អនុវត្តស្របទៅតាមគោលការណ៍ណែនាំរបស់មន្ទីរ និងក្រសួង។ ហេតុដូចច្នេះ អាចវាយតម្លៃបានថា ការបង្កើតក្រុមការងារទទួលបន្ទុករៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង អាចធានាបាននូវដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំប្រកបដោយប្រសិទ្ធភាព។ តាមលទ្ធផលដែលទទួលបានពី ការសម្ភាសន៍បុគ្គលិកអប់រំនៅមន្ទីរ និងក្រសួងអប់រំយុវជន និងកីឡា លើកឡើងថា៖

*"...គណៈកម្មការដឹកនាំ គណៈកម្មការបច្ចេកទេស គណៈកម្មការគាំទ្របច្ចេកទស ក្រុមលេខាធិការដ្ឋាន..."*

*"...ក) គណៈកម្មការដឹកនាំ មានភារកិច្ច ធ្វើសេចក្តីលើខ្លឹមសារនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំនៃរដ្ឋបាលក្រុង ស្រុក ដឹកនាំគ្រប់គ្រងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ ខ) គណៈកម្មការបច្ចេកទេស មានភារកិច្ចរៀបចំក្របខណ្ឌពេលវេលានិងកិច្ចប្រជុំ រៀបចំសេចក្តីព្រាងផែនការ និងកែសម្រួលខ្លឹមសារសេចក្តីព្រាង គ) គណៈកម្មការគាំទ្របច្ចេកទេស មានតួនាទីគាំទ្រផ្នែកបច្ចេកទេស ផ្តល់ធាតុចូលតម្រង់ទិសលើការរៀបចំផែនការយុទ្ធសាស្ត្រ ឱ្យមានសង្គតិភាពថ្នាក់ជាតិ ឃ) ក្រុមលេខាធិការដ្ឋានតួនាទី រៀបចំលិខិតរដ្ឋបាល ព្រាងផែនការយុទ្ធសាស្ត្រ សម្របសម្រួលធ្វើរបាយការណ៍ សកម្មភាពគាំទ្រផ្សេងៗ..."*

### ៤.១.៤ ការរៀបចំក្របខណ្ឌការងារសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

តាមរយៈលទ្ធផលស្រាវជ្រាវបានរកឃើញថា ការិយាល័យអប់រំ យុវជន និងកីឡាក្រុង នៅពុំទាន់យល់ច្បាស់នៅឡើយអំពីការរៀបចំក្របខណ្ឌការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ទាក់ទងនឹងបញ្ហានេះ អាចមានមូលហេតុជាច្រើន ទី១ មិនទាន់យល់ដឹងពីគោលបំណងនៃការរៀបចំក្របខណ្ឌការងារ ទី២ មិនទាន់យល់ដឹងអំពីដំណើរការរៀបចំផែនការ ទី៣ មិនទាន់មានបទពិសោធក្នុងរៀបចំកម្មវិធីការងាររៀបចំផែនការ ទី៤ មិនទទួលបានការណែនាំច្បាស់លាស់អំពីបច្ចេកទេសលើការរៀបចំក្របខណ្ឌការងារ។ យោងតាមលទ្ធផលដែលទទួលបានពី ការសម្ភាសន៍បុគ្គលិកអប់រំនៅការិយាល័យអប់រំ យុវជន និងកីឡាបានលើកឡើងថា៖

*"...រៀងរាល់ឆ្នាំសម្រាប់ធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំនៅដើមឆ្នាំសិក្សា សម្រាប់ផែនការយុទ្ធសាស្ត្រមានការណែនាំ ឬមានការចូលរួមពីមន្ទីរ ក្រសួង ទាំងអស់នេះមន្ត្រីទទួលបន្ទុកជាអ្នករៀបចំ..."*

*"...កំណត់ពេលវេលាជួបប្រជុំ គ្រប់ផ្នែកនីមួយៗត្រូវប្រមូលនិងផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់ទាន់ពេល..."*

*"...ការកំណត់កាលបរិច្ឆេទច្បាស់លាស់ ការកំណត់ទីតាំងសមស្រប កំណត់សមាសភាពចូលរួមការចូលរួមសហការ ការរៀបចំប្រជុំធ្វើសេចក្តីព្រាង ការឆ្លងផែនការ ការប្រជុំសម្រេច..."*

*"...បានណាត់ប្រជុំជាមួយអ្នកពាក់ព័ន្ធ កំណត់រយៈពេលប្រមូលទិន្នន័យ កំណត់ទីតាំងប្រជុំ..."*

*"...មន្ត្រីទទួលបន្ទុកផែនការទទួលពីមន្ទីរមកផ្សព្វផ្សាយដល់មន្ត្រីពាក់ព័ន្ធ មន្ត្រីពាក់ព័ន្ធពិនិត្យលើផ្នែកពាក់ព័ន្ធរបស់ខ្លួន រួចបំពេញជូនមន្ត្រីទទួលបន្ទុកផែនការវិញ ក្រោយពីមន្ត្រីផែនការរៀបចំរួចត្រូវឆ្លងប្រធានពិនិត្យនិងកែសម្រួលដាក់ឱ្យមន្ត្រីពិនិត្យឡើងវិញ ដាក់ជូនអភិបាលក្រុង..."*

*"...ប្រជុំកំណត់ការជួបជុំតាមសមាសភាពគណៈកម្មការច្បាស់លាស់ កំណត់ពេលវេលាជួបប្រជុំពីគ្រប់អនុវិស័យ និងអ្នកពាក់ព័ន្ធ កំណត់រយៈពេលជួបប្រជុំប្រមូលទិន្នន័យពីក្រុមការងារ កំណត់នូវទីតាំង កាលបរិច្ឆេទច្បាស់លាស់ កំណត់ពីចំនួនអ្នកចូលរួមតាមគណៈកម្មការជាក់ស្តែង កំណត់ពីតួនាទីគណៈកម្មការចូលរួមពិភាក្សា និងឆ្លងផែនការនូវសេចក្តីព្រាង..."*

តាមលទ្ធផលដែលបានរកឃើញរបស់មន្ទីរ និងក្រសួង បង្ហាញថា ការរៀបចំក្របខណ្ឌការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុងនៅពុំទាន់យល់ដឹងច្បាស់អំពីគោលការណ៍ក្នុងការរៀបចំក្របខណ្ឌការងាររៀបចំផែនការនៅឡើយ និងនៅមានចំណុចខ្វះខាតជាច្រើន។ បញ្ហានេះអាចមកពីមន្ត្រីទទួលបន្ទុករៀបចំផែនការ និងអ្នកពាក់ព័ន្ធនៅពុំទាន់យល់ដឹងច្បាស់អំពី ១) គោលបំណងនៃការរៀបចំក្របខណ្ឌការងារផែនការអប់រំ ២) ដំណើរការកសាងផែនការអប់រំប្រកបដោយគុណភាព និង៤) យន្តការក្នុងការរៀបចំផែនការអប់រំដែលមានប្រសិទ្ធភាព។ តាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅមន្ទីរ និងក្រសួងអប់រំយុវជន និងកីឡាបានលើកឡើងថា៖

*"...រៀបចំក្របខណ្ឌពេលវេលា និងកម្មវិធីការងារច្បាស់លាស់តាមកាលកំណត់ និងអនុវត្តការរៀបចំតាមការគ្រោងរបស់គណៈកម្មការ។ ក្របខណ្ឌពេលវេលា និងកម្មវិធីការងារ មានដូចជា កំណត់ការជួបប្រជុំតាមសមាសភាព គណៈកម្មការច្បាសលាស់ កំណត់ពេលវេលាជួបជុំពីគ្រប់អនុវិស័យ និងអ្នកពាក់ព័ន្ធកំណត់ពេលវេលាប្រមូលទិន្នន័យពីក្រុមការងារ ការរៀបចំធ្វើសេចក្តីព្រាង ការប្រជុំឆ្លងផែនការ និងការប្រជុំសម្រេច..."*

*"...រៀបចំក្របខណ្ឌការងារស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ថ្នាក់ជាតិ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ថ្នាក់រាជធានីខេត្ត ដោយឆ្លុះបញ្ចាំងពីអាទិភាព និងអន្តរាគមន៍ចាំបាច់នៅកម្រិតថ្នាក់ក្រោមជាតិ រួមទាំងការកំណត់ចក្ខុវិស័យ បេសកកម្ម វត្ថុបំណងរបស់អនុវិស័យយុទ្ធសាស្ត្រ សកម្មភាព សូចនាករនិងចំណុចដៅ និងធនធានគាំទ្រពីអ្នកពាក់ព័ន្ធ ដើម្បីប្រតិបត្តិការការងារតាមអនុវិស័យ និងផ្នែកគាំទ្រ..."*

### ៤.១.៥ ខ្លឹមសារ ឬទម្រង់នៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

ផ្អែកតាមលទ្ធផលស្រាវជ្រាវបានរកឃើញថា អ្នកពាក់ព័ន្ធនៅការិយាល័យអប់រំ យុវជន និងកីឡាក្រុងភាគច្រើន នៅពុំទាន់យល់ដឹងច្បាស់អំពីខ្លឹមសារ ឬទម្រង់នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ប្រការនេះ

អាចបណ្ដាលមកពី មិនទទួលបានការណែនាំ ឬតម្រង់ទិសលើការរៀបចំផែនការអប់រំ មិនធ្លាប់ទទួលបានការអភិវឌ្ឍសមត្ថភាពលើការកសាងផែនការអប់រំ មិនមានបទពិសោធក្នុងការរៀបចំផែនការអប់រំ ឬសមត្ថភាពមន្ត្រីអប់រំមិនទាន់បំពេញតាមលក្ខខណ្ឌការងារ។ យោងតាមលទ្ធផលដែលទទួលបានពី ការសម្ភាសន៍បុគ្គលិកអប់រំនៅការិយាល័យអប់រំ យុវជន និងកីឡា បានលើកឡើងថា៖

*"...សេចក្ដីផ្ដើម គោលនយោបាយ ការរៀបចំតាមអនុវិស័យ ការគ្រប់គ្រង និងអភិវឌ្ឍន៍សមត្ថភាពផែនការហិរញ្ញវត្ថុ ការពិនិត្យតាមដាន និងវាយតម្លៃ..."*

*"...ផ្នែកស្ថិតិបុគ្គលិក ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ ផ្នែកបឋម មធ្យម អប់រំក្រៅប្រព័ន្ធ កុមារតូច ផ្នែកទាំងអស់នេះ សុទ្ធតែពាក់ព័ន្ធទាំងអស់ ដើម្បីឱ្យដំណើរការអភិវឌ្ឍវិស័យអប់រំបានរីកចម្រើនប្រសើរឡើង..."*

*"...ការរីកចម្រើនក្នុងអង្គភាពនៅក្នុងតំណាក់កាលនោះ វិធីសាស្ត្រនៃការកែលម្អ រីកចម្រើន ទិសដៅគ្រប់ផ្នែក..."*

*"...ចំនួន១៣ផ្នែក៖ ១) ផ្នែកអារម្ភកថា ២) មាតិកា ៣) សេចក្ដីផ្ដើម ៤) ប្រវត្តិ ៥) ចក្ខុវិស័យ ៦) បេសកកម្ម ៧) ស្ថាភាពបច្ចុប្បន្ន ឬ បញ្ហាប្រឈម ៨) គោលបំណង ៩) តម្រូវការហិរញ្ញវត្ថុ ឬ ហិរញ្ញប្បទាន ១០) ចំណុចដៅ ១១) យុទ្ធសាស្ត្រសកម្មភាព ១២) ពិនិត្យតាមដានវាយតម្លៃ..."*

*"...មាន១១ផ្នែក៖ ១) សេចក្ដីផ្ដើម ២) ប្រវត្តិការិ.អយក ៣) ចក្ខុវិស័យ ៤)បេសកកម្ម ៥) វិភាគស្ថានភាពអប់រំ និងបញ្ហាប្រឈម ៦) គោលបំណង ៧) សូចនាករ និងចំណុចដៅ ៨) យុទ្ធសាស្ត្រ និងសកម្មភាព ៩) តម្រូវការហិរញ្ញប្បទាន ១០) យន្តការពិនិត្យតាមដាននិងវាយតម្លៃ..."*

តាមការពិនិត្យផ្ទៀងផ្ទាត់ទៅលើលទ្ធផលដែលបានរកឃើញនៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡាក្រុង ជាមួយនឹងលទ្ធផលដែលបានរកឃើញនៅកម្រិតមន្ទីរ និងក្រសួង អាចវាយតម្លៃបានថាអ្នកពាក់ព័ន្ធនៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង នៅពុំទាន់យល់ដឹងច្បាស់លើខ្លឹមសារ ឬទម្រង់នៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ តាមគោលការណ៍ណែនាំដែលផ្ដល់ដោយមន្ទីរ ឬក្រសួងនោះទេ។ បញ្ហានេះអាចមកពី ទី១ មិនទទួលបានការតម្រង់ទិស ឬមិនទទួលបានការណែនាំច្បាស់លាស់លើការរៀបចំផែនការ និងទី២ មិនទទួលបានការគាំទ្របច្ចេកទេសបន្ថែម។ តាមលទ្ធផលដែលទទួលបានពីការ

សម្ភាសន៍បុគ្គលិកអប់រំនៅមន្ទីរ និងក្រសួងអប់រំយុវជន និងកីឡាបានលើកឡើងថា៖

*"...មាន៦ជំពូក៖ ជំពូកទី១ សេចក្ដីផ្ដើម និងការវិភាគការបំពេញការងារ២០១៥-២០១៨ ជំពូកទី២ អាទិភាពនៃការអភិវឌ្ឍរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគោលនយោបាយអប់រំ ២០១៩-២០២៣ និងចក្ខុវិស័យឆ្នាំ២០៣០ ស្ដីពីការអប់រំនៅកម្ពុជា និងផែនការអភិវឌ្ឍ/កម្មវិធីវិនិយោគរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ (៣-៥ឆ្នាំ) ជំពូកទី៣ ផែនការតាមអនុវិស័យឆ្នាំ២០១៩-២០២៣ ជំពូកទី៤ ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជំពូកទី៥ ផែនការហិរញ្ញប្បទាន២០១៩-២០២៣ និងជំពូកទី៦ ការពិនិត្យតាមដាននិងវាយតម្លៃ..."*

### ៤.១.៦ លំដាប់លំដោយអំពីដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

ពាក់ព័ន្ធនឹងលទ្ធផលស្រាវជ្រាវបានរកឃើញថា ការិយាល័យអប់រំ យុវជន និងកីឡាក្រុង យល់ដឹងច្បាស់អំពីលំដាប់លំដោយនៃដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដូចជាប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ បង្កើតគណៈកម្មការរៀបចំផែនការនិងកំណត់តួនាទីភារកិច្ចច្បាស់លាស់ ប្រជុំរៀបចំផែនការជាមួយអ្នកពាក់ព័ន្ធតាមអនុវិស័យ ប្រជុំឆ្លងផែនការ និងប្រជុំសម្រេចមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ។ យោងតាមលទ្ធផលដែលទទួលបានពី ការសម្ភាសន៍បុគ្គលិកអប់រំនៅការិយាល័យអប់រំ យុវជន និងកីឡា បានលើកឡើងថា៖

*"...ប្រជុំផ្សព្វផ្សាយអំពីការធ្វើផែនការ បង្កើតគណៈកម្មការ ប្រជុំបែងចែកក្រុមការងារ ប្រជុំរៀបចំផែនការជាមួយអ្នកពាក់ព័ន្ធតាមអនុវិស័យ អញ្ជើញអ្នកពាក់ព័ន្ធចូលរួមប្រជុំឆ្លង..."*

*"...ប្រជុំជាមួយអ្នកពាក់ព័ន្ធពីការរៀបចំផែនការ បង្កើតគណៈកម្មការចូលរួមគ្រោតធ្វើផែនការ បែងចែកក្រុមគណៈកម្មការតាមផ្នែកនិងតួនាទី កំណត់តួនាទីគណៈកម្មការច្បាស់លាស់ ប្រជុំរៀបចំផែនការ ប្រជុំឆ្លងផែនការ ប្រជុំសម្រេច..."*

*"...ប្រជុំជាមួយអភិបាលក្រុងដើម្បីផ្សព្វផ្សាយ ប្រជុំរៀបចំបង្កើតគណៈកម្មការធ្វើផែនការ វិភាគទិន្នន័យដែលប្រមូលបានពីតាមសាលារៀន ប្រជុំគ្រប់អ្នកពាក់ព័ន្ធដើម្បីធ្វើផែនការ ប្រជុំឆ្លងផែនការសម្រេចគ្រប់អ្នកពាក់ព័ន្ធ..."*

*"...ប្រជុំផ្សព្វផ្សាយពីការរៀបចំផែនការ និងទទួលលិខិតផ្សេងៗ បង្កើតសមាសភាពគណៈកម្មការ បានចូលរួម និងអ្នកពាក់ព័ន្ធ ប្រជុំបែងចែកគណៈកម្មការ និងកំណត់ពីតួនាទីតាមក្រុមពិភាក្សា ប្រជុំរៀបចំផែនការពីគ្រប់អនុវិស័យ និងអ្នកពាក់ព័ន្ធដើម្បីប្រមូលទិន្នន័យ និងប្រឹក្សាយោបល់ពីផែនការ រៀបចំលិខិតអញ្ជើញអ្នកពាក់ព័ន្ធចូលរួមប្រជុំឆ្លងផែនការរួមគ្នាតាមការកំណត់ពេលវេលាណាមួយច្បាស់លាស់ ប្រជុំសម្រេចផែនការយុទ្ធសាស្ត្ររួមគ្នាពីអ្នកពាក់ព័ន្ធ..."*

លទ្ធផលដែលបានរកឃើញនៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្របទៅនឹងលទ្ធផលដែលបានរកឃើញនៅកម្រិតមន្ទីរ និងក្រសួងផងដែរ។ ការយល់ដឹងច្បាស់លើដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយសារការិយាល័យអប់រំ យុវជន និងកីឡាក្រុង បានទទួលការណែនាំអំពីខ្លឹមសារនៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងតាមរយៈការចុះបង្វឹកនិងប្រឹក្សាយោបល់ដោយផ្ទាល់ពីមន្ទីរ និងក្រសួង។ ផ្អែកតាមលទ្ធផលដែលទទួលបានពី ការសម្ភាសន៍បុគ្គលិកអប់រំនៅមន្ទីរអប់រំ យុវជន និងកីឡា បានលើកឡើងថា៖

*"...មន្ទីរចេញសេចក្តីណែនាំ និងបានណែនាំឱ្យរៀបចំផែនការ និងរៀបចំខ្លឹមសារតាមលំដាប់លំដោយ ប្រជុំណែនាំពីខ្លឹមសារដែលត្រូវរៀបចំ ចុះបង្វឹកនិងប្រឹក្សាយោបល់ ពិនិត្យសេចក្តីព្រាង និងប្រមូលជាតុចូល ក្រសួងចុះណែនាំបន្ថែម ពិនិត្យបញ្ចប់ និងចុះហត្ថលេខា..."*

### ៤.១.៧ ដំណើរការរៀបចំផែនការអប់រំមុនពេលកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ផ្អែកតាមលទ្ធផលស្រាវជ្រាវបានរកឃើញថា នៅមុនពេលកំណែទម្រង់វិជ្ឈការ និងវិសហមជ្ឈការ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្ថានភាពការងារនៅការិយាល័យមានដំណើរការល្អទាំងការងាររដ្ឋបាល និងការងារបច្ចេកទេស ដោយសារនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីមន្ទីរអប់រំ យុវជន និងកីឡា។ យន្តការក្នុងការរៀបចំផែនការអប់រំមានភាពងាយស្រួល ការិយាល័យអាចបង្កើតក្រុមការងារទទួលបន្ទុកការរៀបចំផែនការដោយខ្លួនឯងនៅកម្រិតក្រុង ឬសុំអន្តរាគមន៍ផ្ទាល់ពីមន្ទីរ។ នៅក្នុងដំណើរការរៀបចំផែនការទទួលបានគោលការណ៍ណែនាំជាក់លាក់ ការតម្រង់ទិសលើការរៀបចំពីមន្ទីរ ឬក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងការគាំទ្របច្ចេកទេសបន្ថែមពីអង្គការ VSO ដែលធ្វើឱ្យដំណើរការរៀបចំផែនការ

ប្រព្រឹត្តទៅបានល្អ និងសម្រេចលទ្ធផលការងារតាមការគ្រោងទុក។ ផ្អែកតាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅការិយាល័យអប់រំ យុវជន និងកីឡា បានលើកឡើងថា៖

*"...ដំណាក់កាលនោះបានរៀបចំផែនការតែមួយប៉ុណ្ណោះ គឺផែនការប្រតិបត្តិប្រចាំឆ្នាំ។ ចាប់ផ្តើមរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំនៅឆ្នាំ២០១៤ ដោយទទួលបានការណែនាំឱ្យរៀបចំពីក្រសួងអប់រំ យុវជន និងកីឡាខេត្ត តាមរយៈមន្ទីរ។ នៅក្នុងដំណើរការរៀបចំ បានទទួលការតម្រង់ទិសលើការរៀបចំពីក្រសួង បន្ទាប់មកបានប្រជុំផ្សព្វផ្សាយដល់ផ្នែកពាក់ព័ន្ធទាំងអស់ និងបានបង្កើតក្រុមការងារទទួលបន្ទុកការរៀបចំផែនការដែលមានសមាសភាពចូលរួមពីផ្នែកជំនាញ អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ..."*

*"...បានទទួលការសម្របសម្រួលពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការចុះជួយគាំទ្របច្ចេកទេសពីក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ VSO..."*

*"...ការអនុវត្តការងារមានភាពងាយស្រួល ដោយសារមានកញ្ចប់ថវិកាដែលគ្រប់គ្រងដោយការិយាល័យផ្ទាល់ ដូច្នេះការអនុវត្តសកម្មភាពការងារអាចធ្វើទៅតាមក្របខណ្ឌពេលវេលា..."*

### ៤.១.៨ ដំណើរការរៀបចំផែនការអប់រំក្នុងពេលកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ពាក់ព័ន្ធនឹងលទ្ធផលស្រាវជ្រាវបានរកឃើញថា ក្នុងពេលកំណែទម្រង់វិជ្ឈការ និងវិសហមជ្ឈការជាដំណាក់កាលនៃការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡា ឱ្យនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក។ ការគ្រប់គ្រងរដ្ឋបាល និងផ្នែកបច្ចេកទេសនៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡា មានភាពលំបាកព្រោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង។ ក្នុងន័យនេះដំណើរការការងារទាំងអស់ត្រូវអនុវត្តទៅតាមបែបបទរដ្ឋបាល ដោយសុំគោលការណ៍ ឬការឯកភាពពីគណៈអភិបាល ដូចជា សម្ភារដំណើរការរដ្ឋបាល ការជួសជុល លទ្ធកម្ម ថវិកាអនុវត្តសកម្មភាព ជាពិសេស កញ្ចប់ថវិកាផ្នែកអប់រំត្រូវបានគ្រប់គ្រងនិងចាត់ចែងដោយរដ្ឋបាលក្រុង។ នៅពេលចាប់ផ្តើមអនុវត្តកំណែទម្រង់វិជ្ឈការ និងវិសហមជ្ឈការ មានបញ្ហាជាច្រើនដែលកើតមានឡើង ដូចជា រដ្ឋបាលក្រុងនៅពុំទាន់យល់ច្បាស់អំពីរចនាសម្ព័ន្ធរបស់វិស័យអប់រំ ដោយបានចាត់ចែង និងប្រើប្រាស់បុគ្គលិកអប់រំមិនត្រឹមត្រូវទៅតាមជំនាញ របៀបវារៈវិស័យអប់រំមិនត្រូវបានដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃការប្រជុំនានារបស់រដ្ឋបាលក្រុង ដោយ

គ្រាន់តែផ្សារភ្ជាប់ការអប់រំនៅក្នុងរបៀបវារៈផ្សេងៗ ឬជាការប្រជុំដាច់ដោយឡែកសម្រាប់តែវិស័យអប់រំ។ ចំពោះការរៀបចំផែនការអប់រំ ការិយាល័យពុំធ្លាប់ទទួលបានការអភិវឌ្ឍសមត្ថភាពលើការកសាងផែនការអប់រំ ទទួលបានត្រឹមតែការតម្រង់លើការរៀបចំផែនការអប់រំតែប៉ុណ្ណោះពីមន្ទីរ ឬក្រសួង។ ចំណែកដំណើរការរៀបចំផែនការនៅពុំទាន់មានការចូលសហការល្អពីគ្រប់ផ្នែកពាក់ព័ន្ធ និងការគាំទ្រលើកទឹកចិត្តពីគណៈអភិបាលនៃរដ្ឋបាលក្រុង។ ផ្អែកតាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅការិយាល័យអប់រំ យុវជន និងកីឡា បានលើកឡើងថា៖

*"...ការិយាល័យមិនទទួលបានការបំប៉នសមត្ថភាពលើការរៀបចំផែនការពីក្រសួងអប់រំ យុវជន និងកីឡា ដោយទទួលបានត្រឹមតែការតម្រង់ទិសលើក្របខណ្ឌការងារនៃការរៀបចំផែនការ..."*

*"...ពាក់ព័ន្ធនឹងការប្រជុំរបស់រដ្ឋបាលក្រុង មិនដែលមានការដាក់បញ្ចូលវិស័យអប់រំនៅក្នុងរបៀបវារៈនៃអង្គប្រជុំនោះទេ មានត្រឹមតែជាការផ្សារភ្ជាប់ការអប់រំលើកឡើងនៅក្នុងអង្គប្រជុំប៉ុណ្ណោះ តែអាចមានការស្នើសុំជាការប្រជុំដាច់ដោយឡែកសម្រាប់វិស័យអប់រំ ដូចជា ទាក់ទងនឹងបញ្ហាកូវីដ-១៩ សាលារៀនជួបការលំបាក ការសម្ពោធសាលារៀន ការសុំប័ណ្ណសរសើរជូនសម្បុរសជន..."*

*"...ការងារមានភាពងាយស្រួលក្នុងការទំនាក់ទំនងជាមួយអាជ្ញាធរដែនដី ដូចជាការបង្កើតគណៈកម្មការសាលារៀន ប៉ុន្តែក្នុងនោះមានភាពលំបាកច្រើន ដូចជា ទី១ ថវិកាសម្រាប់ដំណើរការអង្គភាពមិនបានទាន់ពេលវេលា សម្ភារផ្នែករដ្ឋបាលត្រូវធ្វើលទ្ធកម្ម ហើយក្រោយការធ្វើលទ្ធកម្មសម្ភារទាំងនោះទទួលបានត្រឹមតែ៥០ភាគរយប៉ុណ្ណោះ ទី២ ទម្រង់លិខិតស្នាមរដ្ឋបាល និងបែបបទលិខិតរដ្ឋបាលក្នុងការអនុវត្តបេសកកម្មមានភាពយឺតយ៉ាវ ហើយថវិកាបេសកកម្មបើកមួយត្រីមាសម្តង ទី៣ ការប្រើប្រាស់មន្ត្រីមានលក្ខណៈពហុជំនាញ ចំណែកការងារចាំបាច់ឬបន្ទាន់គឺស្ថិតនៅក្រោមការចាត់តាំងរបស់គណៈអភិបាល ទី៤ លំបាកក្នុងការដោះស្រាយបញ្ហាតែងតាំងនាយក ឬនាយករង ដោយត្រូវចំណាយពេលយូរ សម្រាប់ការិយាល័យអប់រំ យុវជន និងកីឡា ទី៥ ការរៀបចំសំណើសុំដោះស្រាយបញ្ហាអសកម្មរបស់សាលារៀនមិនត្រូវបានដោះស្រាយទាន់ពេល ទី៦ លំបាកក្នុងការងារទំនាក់ទំនងផ្នែករដ្ឋបាលរវាងមន្ទីរ និងរដ្ឋបាលក្រុង ដូចជាបង្គាប់ការតែងតាំងប្រធាន ឬអនុប្រធានការិយាល័យ ការដំលើងឋានន្តរស័ក្តិ ដោយត្រូវសម្រេចពី*

*រដ្ឋបាលក្រុង សម្រាប់ការិយាល័យអប់រំ យុវជន និងកីឡាក្រុងសំរោង ទី៧ លំបាកក្នុងដោះស្រាយការងារបច្ចេកទេស ដោយត្រូវប្រជុំឆ្លង ឬសុំដំណោះស្រាយ ទី៨ ការគ្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុងមិនមានការចូលរួមពីការិយាល័យអប់រំ យុវជន និងកីឡា ដោយគ្រាន់តែផ្ញើឯកសារដែលបានគ្រោងជាសូហ្វកូពី ទី៩ មិនទាន់យល់ច្បាស់ពីរបៀបរបបការងារនៅរដ្ឋបាលក្រុង ទី១០ រដ្ឋបាលក្រុងមិនទាន់យល់ច្បាស់ពីរចនាសម្ព័ន្ធអប់រំ ទី១១ ទំនាក់ទំនងការងារតាមផ្នែកមួយចំនួនមានការលំបាក ...”*

ជារួម លទ្ធផលដែលបានរកឃើញទាក់ទងនឹងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡាក្រុង មានដូចជា ទី១ ក្របខណ្ឌពេលវេលាសម្រាប់ការរៀបចំផែនការដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា នៅមិនទាន់សមស្របទៅតាមដំណើរការនៃការរៀបចំផែនការ ទី២ ពុំទាន់យល់ដឹងស៊ីជម្រៅអំពីយន្តការក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំតាមគោលការណ៍ណែនាំរបស់ក្រសួងឬមន្ទីរ ទី៣ យល់ដឹងច្បាស់អំពីគោលបំណងនិងសារៈសំខាន់នៃការបង្កើតក្រុមការងាររៀបចំផែនការ ដើម្បីគាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឱ្យមានប្រសិទ្ធភាព ទី៤ ពុំទាន់យល់ច្បាស់អំពីការរៀបចំក្របខណ្ឌការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំអាចមិនទទួលបានការណែនាំច្បាស់លាស់អំពីបច្ចេកទេសលើការរៀបចំក្របខណ្ឌការងារ ទី៥ ពុំទាន់យល់ដឹងច្បាស់អំពីខ្លឹមសារ ឬទម្រង់នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយមូលហេតុអាចមិនទទួលបានការណែនាំ ឬតម្រង់ទិសលើការរៀបចំផែនការអប់រំច្បាស់លាស់ ទី៦ យល់ដឹងច្បាស់អំពីលំដាប់លំដោយនៃដំណើរការរៀបចំផែនការ ដោយសារទទួលបានការប្រជុំណែនាំ និងការគាំទ្របច្ចេកបន្ថែមពីមន្ទីរ និងក្រសួង។ នៅមុនពេលកំណែទម្រង់វិជ្ជការ និងវិសហមជ្ឈការ ស្ថានភាពការងាររបស់ការិយាល័យមានភាពល្អប្រសើរទាំងដំណើរការរដ្ឋបាល និងផ្នែកបច្ចេកទេស ដោយនៅក្រោមការគ្រប់គ្រងផ្ទាល់ពីមន្ទីរអប់រំ យុវជន និងកីឡា ហើយដំណើរការរៀបចំផែនការអប់រំក៏ប្រព្រឹត្តទៅបានល្អ ការិយាល័យអាចបង្កើតក្រុមការងារទទួលបន្ទុកការរៀបចំផែនការដោយខ្លួនឯង ទទួលបានគោលការណ៍ណែនាំជាក់លាក់ និងការតម្រង់ទិសលើការរៀបចំពីមន្ទីរ ឬក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងទទួលបានការគាំទ្របច្ចេកទេសបន្ថែមអង្គការ VSO។ ដោយឡែកស្ថានភាពការងាររបស់ការិយាល័យនៅក្នុងពេលកំណែទម្រង់

វិជ្ជាការនិងវិសហមជ្ឈការ មិនសូវមានដំណើរការល្អទាំងការគ្រប់គ្រងរដ្ឋបាល និងផ្នែកបច្ចេកទេស ដោយសារតែមានការផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រងនៅក្រោមរដ្ឋបាលក្រុង ស្រុក។ ដំណើរការការងារទាំងអស់ត្រូវសុំគោលការណ៍ ឬការឯកភាពពីគណៈអភិបាល ដូចជា ដំណើរការរដ្ឋបាល ការជួសជុល លទ្ធកម្ម និងការអនុវត្តសកម្មភាព ព្រោះកញ្ចប់ថវិកាផ្នែកអប់រំទាំងអស់គ្រប់គ្រងនិងចាត់ចែងដោយរដ្ឋបាលក្រុង។ ជាងនេះទៀត នៅពេលចាប់អនុវត្តកំណែទម្រង់វិជ្ជាការ និងវិសហមជ្ឈការ មានបញ្ហាជាច្រើន ដូចជា រដ្ឋបាលក្រុងនៅពុំទាន់យល់ច្បាស់អំពីរចនាសម្ព័ន្ធរបស់វិស័យអប់រំ ការចាត់តាំងនិងប្រើប្រាស់បុគ្គលិកអប់រំមិនត្រូវទៅតាមជំនាញ និងរបៀបវារៈវិស័យអប់រំមិនទាន់ជាអាទិភាពសម្រាប់រដ្ឋបាលក្រុង។ នៅក្នុងដំណើរការរៀបចំផែនការអប់រំ បុគ្គលិកការិយាល័យពុំធ្លាប់ទទួលបានការអភិវឌ្ឍសមត្ថភាពលើការកសាងផែនការអប់រំ ដោយទទួលបានត្រឹមជាការតម្រង់ទិសនិងការចុះជួយគាំទ្រលើការរៀបចំពីមន្ទីរ ឬក្រសួង និងពុំសូវមានការចូលរួមសហការពីផ្នែកពាក់ព័ន្ធ ព្រមទាំងការគាំទ្រលើកទឹកចិត្តពីគណៈអភិបាលនៃរដ្ឋបាលក្រុង។

## ៤.២ សមត្ថភាពក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣

### ៤.២.១ ការបំប៉នសមត្ថភាពផ្នែកបច្ចេកទេសមុនការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

ផ្អែកតាមលទ្ធផលស្រាវជ្រាវបានរកឃើញថា នៅក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា ពុំដែលទទួលបានការបំប៉នសមត្ថភាពផ្នែកបច្ចេកទេសលើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងការជំរុញឱ្យរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដែលជាហេតុនាំឱ្យមន្ត្រីទទួលបន្ទុកការរៀបចំផែនការ និងអ្នកពាក់ព័ន្ធមិនទាន់មានចំណេះដឹងមូលដ្ឋានផ្នែកផែនការអប់រំ និងសមត្ថភាពផ្នែកបច្ចេកទេសគ្រប់គ្រាន់លើការកសាងផែនការអប់រំ។ យោងតាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅការិយាល័យអប់រំ យុវជន និងកីឡា បានលើកឡើងថា៖

*"...មិនទទួលបានការបំប៉នសមត្ថភាពលើផ្នែកបច្ចេកទេសអ្វីទេពីក្រសួង..."*

*"...ចូលរួមពីអង្គការស្ម័គ្រចិត្ត VSO ប្រចាំខេត្តឧត្តរមានជ័យដោយមានការបើកវគ្គបំប៉នផ្សេងៗ..."*

*"...បំប៉នសមត្ថភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំគឺពុំដែលបានចូលរួមជាមួយក្រសួងអប់រំ តែបានចូលរួមជាមួយមន្ទីរអប់រំ និងអង្គការ VSO..."*

ជាមួយគ្នានេះ លទ្ធផលដែលបានរកឃើញនៅថ្នាក់មន្ទីរ និងក្រសួង ស្របទៅនឹងការលើកឡើងរបស់មន្ត្រីថ្នាក់ការិយាល័យ ដែលបញ្ជាក់ថាពុំទទួលបានការបំប៉នសមត្ថភាពលើការកសាងផែនការអប់រំពីក្រសួងក្នុងរយៈពេលច្រើនឆ្នាំមកហើយ ដោយទទួលបានការបំប៉នសមត្ថភាពផ្នែកបច្ចេកទេសលើកសាងផែនការអប់រំពីមន្ទីរតែប៉ុណ្ណោះ។ ផ្អែកតាមលទ្ធផលដែលទទួលបានពី ការសម្ភាសន៍បុគ្គលិកអប់រំនៅមន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងថា៖

*"...បំប៉នសមត្ថភាពលើផ្នែកបច្ចេកទេស ដើម្បីធ្វើទម្រង់ចេញជាសៀវភៅផែនការយុទ្ធសាស្ត្រ..."*

*"...ណែនាំលើខ្លឹមសារសំខាន់ៗ ចុះបង្វឹកនិងប្រឹក្សាយោបល់ ការវិភាគទិន្នន័យ ការរៀបចំខ្លឹមសារយុទ្ធសាស្ត្រនិងសកម្មភាព ផែនការគ្រោងថវិកា..."*

*"...ពុំបានផ្តល់ការបំប៉នសមត្ថភាពលើការកសាងផែនការអប់រំក្នុងរយៈពេលច្រើនឆ្នាំមកហើយ..."*

### ៤.២.២ ការតម្រង់ទិសលើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

ពាក់ព័ន្ធនឹងលទ្ធផលស្រាវជ្រាវបានរកឃើញថា មន្ត្រីផែនការអប់រំ និងអ្នកពាក់ព័ន្ធនៅកម្រិតក្រុងស្រុក បានទទួលការតម្រង់ទិសលើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំពីក្រសួង និងមន្ទីរអប់រំ យុវជន និងកីឡា ដូចជា ទី១ ការណែនាំឱ្យការបង្កើតក្រុមការងារការរៀបចំផែនការ ដោយកំណត់សមាសភាពគណៈកម្មការសំខាន់ៗ៤ រួមមាន គណៈកម្មការដឹកនាំ គណៈកម្មការបច្ចេកទេស គណៈកម្មការគាំទ្របច្ចេកទេស និងក្រុមលេខាធិការដ្ឋាន ទី២ ការរៀបចំក្របខណ្ឌការងារច្បាស់លាស់សម្រាប់ការរៀបចំផែនការ ទី៣ ការណែនាំអំពីខ្លឹមសារ ឬទម្រង់នៃការរៀបចំផែនការ និងបានទទួលការណែនាំបន្ថែមលើផ្នែកបច្ចេកទេសរៀបចំផែនការអប់រំពីអង្គការ VSO ផងដែរ។ ផ្អែកតាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង បានលើកឡើងថា៖

*"...មន្ទីរអប់រំ យុវជន និងកីឡា បានចុះប្រជុំណែនាំលើការរៀបចំផែនការ..."*

*"...ទទួលការណែនាំបន្ថែមពីអង្គការ VSO លើការរៀបចំផែនការ..."*

*"...ចូលរួមប្រជុំជាមួយក្រសួងអប់រំ តាមរយៈការប្រជុំតាម ZOOM ស្តីពីការរៀបចំផែនការប្រតិបត្តិ និងផែនការយុទ្ធសាស្ត្រ..."*

ជាមួយគ្នានេះដែរ តាមការពិនិត្យផ្ទៀងផ្ទាត់លទ្ធផលដែលបានរកឃើញនៅថ្នាក់ក្រុង ស្រុក ជាមួយនឹងលទ្ធផលដែលបានរកឃើញនៅថ្នាក់មន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡា មានភាពស្របគ្នា ដែលក្នុងន័យនេះអាចបញ្ជាក់បានថាថ្នាក់ការិយាល័យក្រុង ពិតជាទទួលបានការតម្រង់ទិសផ្នែកបច្ចេកទេស និងមានមូលដ្ឋានច្បាស់លាស់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣។ ផ្អែកតាមលទ្ធផលដែលទទួលបានពី ការសម្ភាសន៍បុគ្គលិកអប់រំនៅថ្នាក់មន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡាក្រុង បានលើកឡើងថា៖

*"...បង្ហឹកនិងប្រឹក្សាយោបល់ ប្រជុំណែនាំ ចុះជួយសម្របសម្រួល..."*

*"...ផ្តល់ការរៀបចំផែនការសម្រាប់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក រួមទាំងបញ្ចូលទាំងដំណើរការ យន្តការរៀបចំ និងខ្លឹមសារ..."*

*"...តម្រង់ទិសលើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយផ្តោតលើការបង្កើតក្រុមការងាររៀបចំផែនការ ការរៀបចំក្របខណ្ឌការងារច្បាស់លាស់ក្នុងការរៀបចំផែនការ ខ្លឹមសារនៃផែនការ..."*

### ៤.២.៣ ការគាំទ្របច្ចេកទេសលើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

តាមរយៈលទ្ធផលស្រាវជ្រាវបានរកឃើញថា ក្រោយពីក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការតម្រង់ទិសលើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំដល់ថ្នាក់ការិយាល័យក្រុង ដែលធ្វើឡើងតាមរយៈការប្រជុំតាមកម្មវិធី ZOOM រួចមក ទាំងក្រសួង និងមន្ទីរបានបន្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេសបន្ថែមទៀតលើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅតាមការិយាល័យក្រុង តាមរយៈការចុះជួយដោយផ្ទាល់ និងការជួយគាំទ្រពីចម្ងាយ។ សកម្មភាពចុះជួយគាំទ្រនិងប្រឹក្សាយោបល់ដែលផ្តល់ដោយក្រសួង និងមន្ទីរអាចជួយជំរុញឱ្យការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំមានប្រសិទ្ធភាព ជាពិសេស ជួយដល់អ្នកទទួលបន្ទុករៀបចំផែនការ និងអ្នកពាក់ព័ន្ធ បានយល់ដឹងច្បាស់លើបច្ចេកទេសលម្អិតក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំដែលមានគុណភាព។ យោងតាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិក

អប់រំនៅថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង បានលើកឡើងថា៖

*"...ចុះជួយផ្ទាល់ពីមន្ទីរអប់រំ យុវជន និងកីឡា..."*

*"...មន្ទីរចុះពិនិត្យតាមដាន និងជួយផ្តល់យោបល់កែលម្អ..."*

*"...ប្រជុំតាម ZOOM និងមានការចុះជួយណែនាំដោយផ្ទាល់..."*

បើតាមលទ្ធផលដែលបានរកឃើញនៅថ្នាក់មន្ទីរ និងក្រសួង គឺដូចទៅនឹងការលើកឡើងរបស់ថ្នាក់ការិយាល័យក្រុង ដោយមន្ទីរនិងក្រសួងបានផ្តល់ការគាំទ្របច្ចេកទេសក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ តាមរយៈការជួយគាំទ្រដោយផ្ទាល់ដល់ក្រុង ស្រុក គោលដៅមួយចំនួនដែលជួបបញ្ហាប្រឈមនៅក្នុងដំណើរការរៀបចំ ដើម្បីជំរុញឱ្យការរៀបចំមានគុណភាព និងមានប្រសិទ្ធភាព។ ផ្អែកតាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅថ្នាក់មន្ទីរនិងក្រសួងអប់រំ យុវជន និងកីឡាក្រុង បានលើកឡើងថា៖

*"...ចុះជួយផ្ទាល់ ចុះបង្វឹកនិងប្រឹក្សាយោបល់ ណែនាំតាមលិខិត..."*

*"...បានផ្តល់ការគាំទ្របច្ចេកទេសក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដល់ការិយាល័យអប់រំក្រុង ស្រុក តាមរយៈការចុះជួយបង្រៀនធ្វើផែនការយុទ្ធសាស្ត្រ ចែកជាក្រុម..."*

### ៤.២.៤ ចំណេះដឹងមូលដ្ឋាន ឬសមត្ថភាពផ្នែកបច្ចេកទេសក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣

ផ្អែកតាមលទ្ធផលស្រាវជ្រាវបានរកឃើញថា មន្ត្រីថ្នាក់ការិយាល័យក្រុងមានការយល់ដឹងច្បាស់ទៅលើបច្ចេកទេសក្នុងការរៀបចំផែនការអប់រំ ទាំងចំណេះដឹងមូលដ្ឋាន និងសមត្ថភាពផ្នែកបច្ចេកទេសក្នុងការរៀបចំផែនការ ដែលទាមទារឱ្យមាន សមត្ថភាពខ្ពស់ បទពិសោធ រៀបចំគណៈកម្មការ មានទិន្នន័យច្បាស់លាស់ ជាដើម។ តាមការបញ្ជាក់នេះ មន្ត្រីថ្នាក់ការិយាល័យក្រុង មានសមត្ថភាពក្នុងការរៀបចំផែនការអប់រំដែលមានគុណភាព និងប្រសិទ្ធភាព។ តាមលទ្ធផលដែលទទួលបានពី ការសម្ភាសន៍បុគ្គលិកអប់រំនៅថ្នាក់ការិយាល័យ អប់រំ យុវជន និងកីឡាក្រុង បានលើកឡើងថា៖

*"...ត្រូវមានសមត្ថភាពខ្ពស់ មានជំនាញ មានបទពិសោធក្នុងការរៀបចំផែនការ រៀបចំគណៈ-កម្មការ ក្រុមការងារបានត្រឹមត្រូវ មានទិន្នន័យច្បាស់លាស់..."*

*"...ត្រូវមានចំណេះដឹងមូលដ្ឋានអំពីការរៀបចំផែនការយុទ្ធសាស្ត្រ ចេះប្រមូលជាតុចូល ចេះកំណត់សូចនាករ ចេះកំណត់ក្របខណ្ឌពេលវេលា..."*

*"...ត្រូវមានបទពិសោធជាមន្ត្រីផែនការពីមុនមកទើបល្អ ត្រូវមានការទទួលការបំប៉ន ឬវគ្គផ្សេងៗពីការរៀបចំផែនការ មានចំណេះដឹងគ្រប់ផ្នែកផែនការផ្សេងៗ ត្រូវចេះកុំព្យូទ័រអាចទទួលយកបាន ត្រូវចេះផ្តល់យោបល់ និងសហការគ្នា ត្រូវយល់ពីផែនការច្បាស់លាស់..."*

ដោយឡែក លទ្ធផលស្រាវជ្រាវបានរកឃើញថានៅថ្នាក់មន្ទីរ និងក្រសួង ទាក់ទងនឹងការរៀបចំផែនការអប់រំដែលមានគុណភាព ត្រូវមានចំណេះដឹងទូលំទូលាយទៅលើការអភិវឌ្ឍធនធានមនុស្ស ដូចជាគោលនយោបាយអប់រំជាសកល ចក្ខុវិស័យរបស់ជាតិ គោលនយោបាយជាតិ និងគោលនយោបាយរបស់ក្រសួង និងសមត្ថភាពជំនាញ ដូចជា មូលដ្ឋានគ្រឹះក្នុងការរៀបចំផែនការអប់រំ ហេតុវិនិច្ឆ័យ ឬវិភាគស្ថានភាពអប់រំ ការកំណត់សូចនាករនិងចំណុចដៅ កំណត់យុទ្ធសាស្ត្រនិងសកម្មភាព។ យោងតាមការលើកឡើងអាចវាយតម្លៃបានថា សមត្ថភាពក្នុងការរៀបចំផែនការអប់រំរបស់មន្ត្រីថ្នាក់ការិយាល័យក្រុងនៅពុំទាន់គ្រប់គ្រាន់នោះទេ ដែលទាមទារឱ្យមានចំណេះដឹងទូលំទូលាយ ឬសមត្ថភាពផ្នែកបច្ចេកទេសខ្ពស់ ដើម្បីរៀបចំផែនការអប់រំឱ្យមានគុណភាព ស្របទៅតាមគោលការណ៍ណែនាំរបស់ក្រសួង។ ផ្អែកតាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង បានលើកឡើងថា៖

*"...ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ប្រកបដោយគុណភាព ត្រូវមានចំណេះដឹងទូលំទូលាយ និងសមត្ថភាពជំនាញ ដូចជា ការយល់ដឹងអំពីគោលដៅអភិវឌ្ឍធនធានមនុស្សរបស់សកល ចក្ខុវិស័យរបស់ជាតិ គោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេស គោលនយោបាយអប់រំរបស់ក្រសួង យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ទិសដៅអាទិភាពការងារប្រចាំឆ្នាំ មូលដ្ឋានគ្រឹះនៃការរៀបចំផែនការ គោលការណ៍រៀបចំផែនការវិស័យអប់រំប្រកបដោយគុណភាព ហេតុវិនិច្ឆ័យក្នុងវិស័យ អប់រំ ឬវិភាគស្ថានភាពអប់រំ កំណត់សូចនាករគន្លឹះនិង*

*ចំណុចដៅ កំណត់យុទ្ធសាស្ត្រគន្លឹះ រៀបចំកម្មវិធី ឬកំណត់សកម្មភាពអាទិភាព វិភាគនិងធ្វើចំណោលតម្រូវការអប់រំ រៀបចំការអនុវត្តនិងសមត្ថភាពក្នុងអនុវត្ត...”*

*“...ត្រូវមានចំណេះដឹងជាមូលដ្ឋានលើការរៀបចំផែនការ និងសមត្ថភាពផ្នែកបច្ចេកទេស ដូចជា ការយល់ដឹងពីមូលដ្ឋានគ្រឹះនៃការរៀបចំផែនការ ការវិភាគនិងបកស្រាយទិន្នន័យ ការកំណត់សូចនាករនិងចំណុចដៅច្បាស់លាស់ ការកំណត់យុទ្ធសាស្ត្រនិងសកម្មភាព...”*

ជារួម ផ្អែកតាមលទ្ធផលដែលបានរកឃើញនៅកម្រិតក្រុង និងតាមការពិនិត្យផ្ទៀងផ្ទាត់លទ្ធផលជាមួយនឹងថ្នាក់មន្ទីរ និងក្រសួង អាចវាយតម្លៃបានថា មន្ត្រីថ្នាក់ការិយាល័យក្រុងនៅពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំផែនការអប់រំដែលគុណភាព ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងនៅឡើយ ដោយយោងតាមមូលហេតុដែលបានលើកឡើងមួយចំនួន ដូចជា ពុំទាន់មានចំណេះដឹងមូលដ្ឋានក្នុងការរៀបចំផែនការអប់រំ ពុំទាន់ចេះធ្វើហេតុវិនិច្ឆ័យអប់រំ ពុំទាន់យល់ដឹងពីគោលដៅអភិវឌ្ឍធនធានមនុស្សរបស់សកល គោលនយោបាយជាតិ និងគោលនយោបាយអប់រំរបស់ក្រសួងជាដើម។

## ៤.៣ បញ្ហាប្រឈមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

យោងតាមលទ្ធផលស្រាវជ្រាវបានរកឃើញថា ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង នៅពុំទាន់មានគុណភាព និងប្រសិទ្ធភាពនៅឡើយទេ ដោយនៅមានបញ្ហាប្រឈមចម្បងៗជាច្រើន ដូចជា សមត្ថភាពមន្ត្រីរៀបចំផែនការនៅមានកម្រិត ខ្វះការចូលរួមពីអ្នកពាក់ព័ន្ធ និងការគ្រប់គ្រងទិន្នន័យអប់រំនៅពុំទាន់បានល្អ។ តាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅថ្នាក់ក្រុងបានលើកឡើងថា៖

*“...សមត្ថភាពមន្ត្រីការិយាល័យនៅមានកម្រិត...”*

*“...ពិបាកក្នុងការប្រមូលទិន្នន័យ...”*

*“...ខ្វះការចូលរួមពីអ្នកពាក់ព័ន្ធ...”*

ទន្ទឹមនឹងនេះ លទ្ធផលស្រាវជ្រាវដែលបានរកឃើញនៅថ្នាក់មន្ទីរនិងក្រសួង បានបង្ហាញផងដែរថា ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣របស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង

នៅពុំទាន់បានល្អ និងមានប្រសិទ្ធភាពនៅឡើយ ដោយជួបប្រទះឧបសគ្គជាច្រើន ដូចជា ខ្វះចំណេះដឹងលើការកសាងផែនការអប់រំ សមត្ថភាពមន្ត្រីផែនការអប់រំនៅពុំទាន់គ្រប់គ្រាន់ ខ្វះសមត្ថភាពក្នុងការវិភាគស្ថានភាពអប់រំ ការគ្រប់គ្រងទិន្នន័យអប់រំនៅពុំទាន់ល្អ ខ្វះការចូលរួមពីអ្នកពាក់ព័ន្ធ មិនទាន់យល់ច្បាស់ពីការកំណត់សូចនាករនិងចំណុចដៅ និងមិនទាន់យល់ច្បាស់ពីការលើកយុទ្ធសាស្ត្រនិងសកម្មភាព។ ផ្អែកតាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅមន្ទីរនិងក្រសួងបានលើកឡើងថា៖

*"...មន្ត្រីចេញពីគ្រូបង្រៀនធ្វើផែនការមិនមានមូលដ្ឋានគ្រប់គ្រាន់ធ្វើផែនការ ពេលវេលារៀបចំយឺតចេញដោយក្រសួង ការគ្រប់គ្រងទិន្នន័យតាមក្រុង ស្រុក មិនទាន់បានល្អ សមត្ថភាពក្នុងការវិភាគទិន្នន័យមិនទាន់បានល្អ..."*

*"...មន្ត្រីមិនទាន់យល់ដឹងលើមូលដ្ឋានគ្រឹះនៃការធ្វើផែនការ សមត្ថភាពរបស់មន្ត្រីផែនការអប់រំនៅមានកម្រិត សមត្ថភាពក្នុងការវិភាគស្ថានភាពអប់រំនៅមិនទាន់ល្អ មិនទាន់មានចំណេះដឹងលើផ្នែកវិភាគនិងបកស្រាយទិន្នន័យ មិនទាន់យល់ដឹងច្បាស់អំពីការលើកយុទ្ធសាស្ត្រនិងសកម្មភាពដែលឆ្លើយតបការគ្រប់គ្រងទិន្នន័យអប់រំនៅតាមក្រុង ស្រុក នៅមិនទាន់បានល្អ លិខិតជូនដំណឹងស្តីពីការរៀបចំចេញដោយក្រសួងយឺតពេល..."*

*"...តាមរយៈការចុះជួយគាំទ្របច្ចេកទេសដោយផ្ទាល់ ឬពីចម្ងាយលើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣របស់ថ្នាក់ក្រុង ស្រុក រួមមាន ខ្វះចំណេះដឹងលើការកសាងផែនការអប់រំ ខ្វះបទពិសោធក្នុងការរៀបចំ មន្ត្រីផែនការអប់រំថ្នាក់ស្រុក មិនទទួលបានការអភិវឌ្ឍសមត្ថភាពក្នុងការកសាងផែនការអប់រំក្នុងរយៈពេល៥ឆ្នាំចុងក្រោយ មន្ត្រីរៀបចំផែនការអប់រំមានការផ្លាស់ប្តូរ ដោយសារស្ថិតនៅក្នុងបរិបទនៃការធ្វើកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ពុំសូវទទួលបានការគាំទ្របច្ចេកទេសពីថ្នាក់មន្ទីរ មិនទាន់យល់ដឹងច្បាស់លើខ្លឹមសារ ឬទម្រង់នៃការរៀបចំផែនការ ដំណើរការបង្កើតក្រុមការងាររៀបចំផែនការត្រូវចំណាយយូរ ការចូលរួមសហការពីផ្នែកពាក់ព័ន្ធនៅមិនទាន់បានល្អ ពិបាកស្រាវជ្រាវរកទិន្នន័យដែលបានអនុវត្តច្រើនឆ្នាំមកហើយ មិនទាន់យល់ច្បាស់ពីការសរសេរវិភាគនិងបកស្រាយទិន្នន័យមិនទាន់យល់ច្បាស់លើការកំណត់សូចនាករនិងចំណុចដៅ និងការលើកយុទ្ធសាស្ត្រ..."*

ជារួម ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣របស់ការិយាល័យក្រុង នៅពុំទាន់មានប្រសិទ្ធភាពនិងគុណភាពនៅឡើយ ដោយនៅមានបញ្ហាប្រឈមជាច្រើន រួមមាន សមត្ថភាពមន្ត្រីរៀបចំផែនការនៅពុំទាន់គ្រប់គ្រាន់ ខ្វះសមត្ថភាពក្នុងការវិភាគស្ថានភាពអប់រំ ការគ្រប់គ្រងទិន្នន័យអប់រំនៅពុំទាន់ល្អ ខ្វះការចូលរួមពីអ្នកពាក់ព័ន្ធ មិនទាន់យល់ច្បាស់ពីការកំណត់សូចនាករនិងចំណុចដៅ និងមិនទាន់យល់ច្បាស់ពីការលើកយុទ្ធសាស្ត្រនិងសកម្មភាពដែលឆ្លើយតប។

## ៤.៤ ដំណោះស្រាយ និងមតិយោបល់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

### ៤.៤.១ ដំណោះស្រាយនៅក្នុងដំណើរការរៀបចំផែនការអប់រំ

ពាក់ព័ន្ធនឹងលទ្ធផលស្រាវជ្រាវបានរកឃើញថា ការិយាល័យអប់រំ យុវជន និងកីឡាក្រុង អាចដោះស្រាយញ្ហាប្រឈមដែលកើតមានឡើងនៅក្នុងដំណើរការរៀបចំផែនការអប់រំរបស់ខ្លួន ដោយប្រើប្រាស់យន្តការសម្របសម្រួលផ្ទៃក្នុងរបស់ការិយាល័យ តាមរយៈការប្រជុំណែនាំពីរបៀបរៀបចំផែនការអប់រំដល់អ្នកពាក់ព័ន្ធឱ្យបានយល់ច្បាស់លាស់ កំណត់ពេលវេលាក្នុងការរៀបចំផែនការតាមអនុវិស័យ និងអញ្ជើញគ្រប់អ្នកពាក់ព័ន្ធចូលរួមប្រជុំរៀបចំផែនការ។ ដើម្បីឱ្យយន្តការដោះស្រាយបញ្ហានេះកាន់តែមានប្រសិទ្ធភាព ការិយាល័យ ចាំបាច់ត្រូវពង្រឹងលើការអនុវត្តតួនាទីនិងភារកិច្ចរបស់ក្រុមការងារទទួលបន្ទុករៀបចំផែនការអប់រំ និងជំរុញឱ្យមានការគាំទ្រនិងលើកទឹកចិត្តពីថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង។ ផ្អែកតាមលទ្ធផលដែលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅកម្រិតក្រុងបានលើកឡើងថា៖

*"...កំណត់ពេលវេលាច្បាស់លាស់ក្នុងការជុំគ្នារៀបចំផែនការតាមអនុវស័យនិងអ្នកពាក់ព័ន្ធ..."*

*"...អញ្ជើញអ្នកពាក់ព័ន្ធចូលរួមប្រជុំដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ..."*

*"...ពន្យល់ណែនាំពីរបៀបធ្វើផែនការឱ្យបានច្បាស់លាស់ឱ្យបានច្បាស់លាស់..."*

ជាមួយគ្នានេះដែរ តាមលទ្ធផលស្រាវជ្រាវដែលបានរកឃើញនៅកម្រិតមន្ទីរ និងក្រសួង បង្ហាញថាបញ្ហាប្រឈមនៅក្នុងដំណើរការរៀបចំផែនការអប់រំរបស់ថ្នាក់ការិយាល័យ ត្រូវបានយកចិត្តទុកដាក់និងដោះស្រាយដោយក្រសួងនិងមន្ទីរផងដែរ តាមរយៈចូលរួមប្រជុំណែនាំជាមួយផ្នែកជំនាញនិងអ្នកពាក់ព័ន្ធ

ការចុះជួយគាំទ្រលើការងារបច្ចេកទេស រួមទាំងការផ្តល់គំរូឯកសារនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ថ្នាក់មន្ទីរ ដើម្បីមានមូលដ្ឋានក្នុងការរៀបចំ។ យោងតាមលទ្ធផលដែលទទួលបានពី ការសម្ភាសន៍បុគ្គលិកអប់រំនៅកម្រិតមន្ទីរ និងក្រសួងបានលើកឡើងថា៖

*"...បានចុះជួយទៅតាមលទ្ធភាពជាក់ស្តែងលើការងារបច្ចេកទេសធ្វើផែនការ បានផ្តល់គំរូនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣របស់ថ្នាក់មន្ទីរទៅដល់ក្រុង ស្រុក ដើម្បីបានគំរូក្នុងការរៀបចំ និងបានផ្តល់ការណែនាំឱ្យប្រជុំជាមួយផ្នែកជំនាញ និងអ្នកពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូល បានចូលរួមប្រជុំណែនាំជាប្រចាំ បានសម្របសម្រួលនិងសហការជាមួយមន្ទីរ..."*

*"...ជំរុញឱ្យមន្ទីរអប់រំ យុវជន និងកីឡា ចុះជួយណែនាំបន្ថែមនៅតាមការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក និងបន្តជួយគាំទ្របច្ចេកទេសដោយផ្ទាល់ ឬពីចម្ងាយ ហើយក្រសួងក៏បានចុះជួយគាំទ្របច្ចេកទេសដោយផ្ទាល់នៅតាមការិយាល័យអប់រំ យុវជន និងកីឡា និងបន្តគាំទ្របច្ចេកពីចម្ងាយដល់ថ្នាក់ក្រុង ស្រុក និងមន្ទីរ..."*

### ៤.៤.២ មតិយោបល់ដើម្បីឱ្យការរៀបចំផែនការអប់រំមានប្រសិទ្ធភាព និងគុណភាព

តាមរយៈលទ្ធផលស្រាវជ្រាវបានរកឃើញថា ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣របស់ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង នាពេលកន្លងមក ជួបបញ្ហាប្រឈមចម្បងៗជាច្រើន ដូចជា សមត្ថភាពមន្ត្រីរៀបចំផែនការនៅពុំទាន់គ្រប់គ្រាន់ ខ្វះសមត្ថភាពក្នុងការវិភាគស្ថានភាពអប់រំ ការគ្រប់គ្រងទិន្នន័យអប់រំនៅពុំទាន់ល្អ និងខ្វះការចូលរួមពីអ្នកពាក់ព័ន្ធ ហេតុនេះហើយធ្វើឱ្យការរៀបចំផែនការអប់រំនៅថ្នាក់ក្រុងនៅពុំទាន់មានប្រសិទ្ធភាព។ ដើម្បីពង្រឹងលើការរៀបចំផែនការអប់រំនៅអណត្តិក្រោយៗឱ្យមានប្រសិទ្ធភាព និងគុណភាព ការរៀបចំផែនការអប់រំគួររៀបចំឱ្យស្របទៅតាមដំណាក់កាលនៃការរៀបចំផែនការ ផ្តល់ការអភិវឌ្ឍសមត្ថភាពលើការរៀបចំផែនការអប់រំដល់មន្ត្រីទទួលបន្ទុករៀបចំផែនការនិងអ្នកពាក់ព័ន្ធ ពង្រឹងប្រសិទ្ធភាពការអនុវត្តការងាររបស់ក្រុមការងាររៀបចំផែនការអប់រំ ពង្រឹងលើការគ្រប់គ្រងទិន្នន័យអប់រំឱ្យច្បាស់លាស់ និងពង្រឹងលើការចូលរួមរៀបចំផែនការរបស់គ្រប់អ្នកពាក់ព័ន្ធ។ ផ្អែកតាមលទ្ធផលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅកម្រិតក្រុងបានលើកឡើងថា៖

"...រៀបចំវគ្គបណ្តុះបណ្តាលពេញលេញពីរបៀបរៀបចំផែនការយុទ្ធសាស្ត្រដល់មន្ត្រីជំនាញ..."

"...បង្កើតគណៈកម្មការច្បាស់លាស់ មានសមត្ថភាពផ្នែកផែនការ មានការចូលរួមនិងសហការល្អពីអ្នកពាក់ព័ន្ធ កំណត់ក្របខណ្ឌពេលវេលាច្បាស់លាស់..."

"...មន្ត្រីទទួលបន្ទុកត្រូវមានសមត្ថភាពក្នុងការងាររៀបចំផែនការ មានក្របខណ្ឌពេលវេលាច្បាស់លាស់ក្នុងការរៀបចំផែនការ កំណត់ការរៀបចំសមាសភាពចូលរួមច្បាស់លាស់..."

"...ធ្វើផែនការតាមកម្មវិធីដែលបានកំណត់ គ្រប់ទិន្នន័យទាំងអស់មានភាពច្បាស់លាស់ ក្រសួង ឬមន្ទីរត្រូវជូនលិខិតនិងជូនដំណឹងឱ្យបានទាន់ពេល..."

ទន្ទឹមនឹងនេះ លទ្ធផលដែលបានរកឃើញនៅថ្នាក់មន្ទីរ និងក្រសួង ស្របទៅនឹងមតិយោបល់របស់ថ្នាក់ការិយាល័យផងដែរ ដើម្បីដោះស្រាយបញ្ហាប្រឈមចម្បងៗដែលកើតមាននៅក្នុងដំណើរការរៀបចំផែនការអប់រំនាពេលកន្លងមក និងពង្រឹងការរៀបចំផែនការអប់រំប្រកបដោយប្រសិទ្ធភាព និងគុណភាពនៅពេលក្រោយៗទៀត គួរចេញសេចក្តីណែនាំក្នុងការរៀបចំផែនការឱ្យបានទាន់ពេល រៀបចំទម្រង់នៃការរៀបចំផែនការឱ្យងាយយល់និងច្បាស់លាស់ ពង្រឹងលើការប្រមូលនិងចងក្រងទិន្នន័យអប់រំឱ្យបានល្អ តម្រង់ទិសលើការរៀបចំផែនការអប់រំដល់មន្ត្រីទទួលបន្ទុករៀបចំនិងអ្នកពាក់ព័ន្ធ ណែនាំលើការសរសេរវិភាគនិងបកស្រាយទិន្នន័យ និងផ្តល់ការគាំទ្របច្ចេកទេសបន្ថែមលើការរៀបចំផែនការ។ ផ្អែកតាមលទ្ធផលទទួលបានពីការសម្ភាសន៍បុគ្គលិកអប់រំនៅថ្នាក់មន្ទីរ និងក្រសួងបានលើកឡើងថា៖

*"...ចេញសេចក្តីណែនាំឱ្យបានទាន់ពេលវេលា ចុះជួយគាំទ្របច្ចេកទេស ប្រជុំណែនាំតាមដំណាក់កាលនីមួយៗ..."*

*"...សេចក្តីណែនាំក្នុងការរៀបចំឱ្យបានទាន់ពេលវេលា រៀបចំទម្រង់រៀបចំផែនការងាយយល់ច្បាស់លាស់ កុំសង្ខេបពេក តម្រង់ទិសឱ្យបានច្បាស់លាស់..."*

*"...ចំណុចកែលម្អមួយចំនួន មានដូចជា ការពិនិត្យនិងកែសម្រួលលើក្របខណ្ឌពេលវេលា និងក្របខណ្ឌការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឱ្យស្របពេលនឹងថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ រៀបចំទម្រង់ ឬខ្លឹមសារនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឱ្យបានលម្អិតជាងមុន ផ្តល់ការអភិវឌ្ឍសមត្ថភាពលើការ*

*កសាងផែនការអប់រំដល់មន្ត្រីផែនការអប់រំថ្នាក់ក្រុង ស្រុក ឬជំរុញឱ្យមន្ទីរអប់រំ យុវជន និងកីឡាខេត្ត លើកផែនការបំប៉នសមត្ថភាពលើការរៀបចំផែនការអប់រំដល់មន្ត្រីផែនការអប់រំថ្នាក់ក្រុង ស្រុក ពង្រឹងលើការប្រមូលនិងចងក្រងទិន្នន័យអប់រំឱ្យបានល្អ ណែនាំលើការសរសេរវិភាគនិងបកស្រាយទិន្នន័យ...”*

ជារួម បញ្ហាប្រឈមនៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ថ្នាក់ក្រុង ត្រូវបានដោះស្រាយដោយប្រើប្រាស់យន្តការសម្របសម្រួលផ្ទៃក្នុងរបស់ការិយាល័យ និងការជួយគាំទ្របច្ចេកទេសបន្ថែមពីមន្ទីរ និងក្រសួង តាមរយៈការប្រជុំណែនាំជាមួយផ្នែកជំនាញនិងអ្នកពាក់ព័ន្ធពីរបៀបរៀបចំផែនការឱ្យបានច្បាស់លាស់ និងការបង្ហាញពីគំរូឯកសារនៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ថ្នាក់មន្ទីរសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំ។ ដើម្បីពង្រឹងលើការងាររៀបចំផែនការអប់រំឱ្យកាន់តែមានប្រសិទ្ធភាពនិងគុណភាព គួរពង្រឹងលើការអនុវត្តតួនាទីនិងភារកិច្ចរបស់ក្រុមការងារទទួលបន្ទុករៀបចំផែនការអប់រំការរៀបចំទម្រង់នៃការរៀបចំផែនការងាយយល់និងច្បាស់លាស់ ពង្រឹងលើការប្រមូលនិងចងក្រងទិន្នន័យអប់រំឱ្យបានល្អ តម្រង់ទិសលើការរៀបចំផែនការអប់រំដល់មន្ត្រីទទួលបន្ទុករៀបចំនិងអ្នកពាក់ព័ន្ធ ណែនាំលើការសរសេរវិភាគនិងបកស្រាយទិន្នន័យ ផ្តល់ការគាំទ្របច្ចេកទេសបន្ថែមលើការរៀបចំផែនការ និងជំរុញឱ្យមានការគាំទ្រនិងលើកទឹកចិត្តពីថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង។

# ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

នៅក្នុងការសិក្សាស្រាវជ្រាវអំពី ការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ២០១៩-២០២៣ របស់ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុងបាត់ដំបង ខេត្តបាត់ដំបង និងក្រុងសំរោង ខេត្តឧត្តរមានជ័យ បានរកឃើញលទ្ធផលជាច្រើនទាំងចំណុចវិជ្ជមាន និងអវិជ្ជមានទាក់ទងនឹងដំណើរការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ សមត្ថភាពក្នុងការរៀបចំផែនការ និងបញ្ហាប្រឈមចម្បងៗ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវទាំងនេះមានដូចខាងក្រោម៖

**ផ្អែកតាមលទ្ធផលនៃផ្នែកសំណួរស្រាវជ្រាវទី១** ទាក់ទងនឹងដំណើរការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ បង្ហាញថា ទី១ ក្របខណ្ឌពេលវេលាសម្រាប់ការរៀបចំផែនការនៅមិនពុំទាន់សមស្របទៅតាមដំណាក់កាលនៃការរៀបចំផែនការ ទី២ ពុំទាន់យល់ដឹងច្បាស់អំពីយន្តការក្នុងការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំតាមគោលការណ៍ណែនាំរបស់ក្រសួង ឬមន្ទីរ ទី៣ យល់ដឹងច្បាស់អំពីគោលបំណងនិងសារៈសំខាន់នៃការបង្កើតក្រុមការងាររៀបចំផែនការ ដើម្បីគាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំឱ្យមានប្រសិទ្ធភាព ទី៤ ពុំទាន់យល់ច្បាស់អំពីការរៀបចំក្របខណ្ឌការងាររៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ ទី៥ ពុំទាន់យល់ដឹងច្បាស់អំពីខ្លឹមសារ ឬទម្រង់នៃផែនការយុទ្ធសាស្រ្តវិស័យអប់រំ ទី៦ យល់ដឹងច្បាស់អំពីលំដាប់លំដោយនៃដំណើរការរៀបចំផែនការ។ ចំពោះស្ថានភាពការងាររបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង នៅមុនពេលកំណែទម្រង់វិជ្ជការនិងវិសហមជ្ឈការ មានភាពល្អប្រសើរទាំងការគ្រប់គ្រងរដ្ឋបាល និងផ្នែកបច្ចេកទេស។ ផ្ទុយទៅវិញនៅក្នុងអំឡុងពេលអនុវត្តកំណែទម្រង់វិជ្ជការនិងវិសហមជ្ឈការ ស្ថានភាពការងារពុំសូវមានដំណើរការល្អ រួមមាន ខ្វះសម្ភារដំណើរការផ្នែករដ្ឋបាល ការចាត់ចែងនិងប្រើប្រាស់បុគ្គលិកអប់រំពុំសមស្របទៅតាមជំនាញ របៀបវារៈវិស័យអប់រំមិនទាន់ជាអាទិភាព ខ្វះការចូលសហការពីផ្នែកពាក់ព័ន្ធលើការរៀបចំផែនការអប់រំ ពុំសូវទទួលបានការអភិវឌ្ឍសមត្ថភាពលើផ្នែកបច្ចេកទេស មិនមានថវិកាអនុវត្តសកម្មភាពតាមផែនការ និងខ្វះការគាំទ្រលើកទឹកចិត្តពីថ្នាក់ដឹកនាំ។

**ផ្អែកតាមលទ្ធផលនៃសំណួរស្រាវជ្រាវទី២** ពាក់ព័ន្ធនឹងសមត្ថភាពក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅកម្រិតក្រុង បង្ហាញថា មន្ត្រីថ្នាក់ការិយាល័យក្រុងនៅពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំផែនការអប់រំប្រកបដោយប្រសិទ្ធភាព និងមានគុណភាព ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងនៅឡើយ ដោយយោងតាមហេតុផលមួយចំនួន រួមមាន ពុំទាន់មានចំណេះដឹងមូលដ្ឋានក្នុងការរៀបចំផែនការអប់រំ ពុំទាន់ចេះធ្វើហេតុវិនិច្ឆ័យអប់រំ ពុំទាន់យល់ដឹងពីគោលដៅអភិវឌ្ឍធនធានមនុស្សរបស់សកលគោលនយោបាយជាតិ និងគោលនយោបាយអប់រំរបស់ក្រសួងជាដើម។

**ផ្អែកតាមលទ្ធផលនៃសំណួរស្រាវជ្រាវទី៣** ទាក់ទងនឹងបញ្ហាប្រឈមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ បង្ហាញថា ការរៀបចំផែនការអប់រំរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង នៅពុំទាន់មានប្រសិទ្ធភាព និងគុណភាពនៅឡើយ ទោះជាទទួលបានការតម្រង់ទិសលើការរៀបចំផែនការ និងការគាំទ្របច្ចេកទេសបន្ថែមពីក្រសួង និងមន្ទីរ ក៏នៅមានបញ្ហាប្រឈមៗជាច្រើន រួមមាន សមត្ថភាពមន្ត្រីរៀបចំផែនការនៅពុំទាន់គ្រប់គ្រាន់ ខ្វះសមត្ថភាពក្នុងការវិភាគស្ថានភាពអប់រំ ការគ្រប់គ្រងទិន្នន័យអប់រំនៅពុំទាន់ល្អ ខ្វះការចូលរួមពីអ្នកពាក់ព័ន្ធ មិនទាន់យល់ច្បាស់ពីការកំណត់សូចនាករនិងចំណុចដៅ និងមិនទាន់យល់ច្បាស់ពីការលើកយុទ្ធសាស្ត្រនិងសកម្មភាពដែលឆ្លើយតប។

តាមរយៈការសិក្សាស្រាវជ្រាវ បង្ហាញឱ្យឃើញថា ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣របស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុងទាំងពីរ នៅពុំទាន់មានប្រសិទ្ធភាព និងគុណភាពល្អប្រសើរនៅឡើយ ដោយទាមទារនូវការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ការបន្តអភិវឌ្ឍសមត្ថភាពដល់អ្នកទទួលបន្ទុករៀបចំផែនការ ការតម្រង់ទិសលើការរៀបចំនិងការគាំទ្របច្ចេកទេសពីក្រសួងនិងមន្ទីរ ព្រមទាំងការគាំទ្រពីគ្រប់ផ្នែកពាក់ព័ន្ធ និងការចូលរួមលើកទឹកចិត្តពីគណៈអភិបាលនៃរដ្ឋបាលក្រុង។

## ៥.២ សំណូមពរ

- ក្រសួងអប់រំ យុវជន និងកីឡា គួរពិនិត្យនិងកែសម្រួលទម្រង់នៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដែលមានភាពងាយស្រួលក្នុងការអនុវត្តតាម និងភ្ជាប់ទម្រង់គំរូ
- ក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡា គួរផ្តល់ការអភិវឌ្ឍសមត្ថភាពលើការកំណត់យុទ្ធសាស្ត្រគន្លឹះ ការលើកសកម្មភាពអាទិភាព ការកំណត់សូចនាករនិងចំណុចដៅច្បាស់លាស់ និងវិធីសាស្ត្រក្នុងការធ្វើចំណោលចំណុចដៅសូចនាករដល់មន្ត្រីផែនការអប់រំថ្នាក់ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធ
- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវពិភាក្សាជាមួយក្រសួងមហាផ្ទៃ ដើម្បីកំណត់យកវិស័យអប់រំជាវិស័យអាទិភាព ក្នុងក្របខណ្ឌថវិការបស់រដ្ឋបាលស្រុក ក្រុង ខណ្ឌ និងធ្វើសមារណកម្មផែនការយុទ្ធសាស្ត្រវិស័យអប់រំ ទៅក្នុងផែនការរដ្ឋបាលស្រុក ក្រុង ខណ្ឌ ដោយមានការពិនិត្យតាមដាន និងវាយតម្លៃ
- ក្រសួងគួរជម្រុញការប្រើប្រាស់ការស្រាវជ្រាវខ្នាតតូច ឬការស្រាវជ្រាវប្រតិបត្តិ ជាមូលដ្ឋានដល់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ យុវជន និងកីឡា ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រឆ្លុះបញ្ចាំងពីបញ្ហាជាក់ស្តែងនៅក្នុងតំបន់នោះ
- គួររៀបចំយន្តការគណនេយ្យភាពឱ្យច្បាស់លាស់ រវាងការិយាល័យអប់រំ យុវជន និងកីឡា ដែលនៅក្រោមរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ជាមួយក្រសួងអយក មន្ទីរអយក និងសាលារៀនពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- គួររៀបចំយន្តការដែលឱ្យមានការចូលរួមរបស់សហគមន៍ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដើម្បីឱ្យផែនការយុទ្ធសាស្ត្រនេះឆ្លុះបញ្ចាំងពីសេចក្តីត្រូវការរបស់សហគមន៍ និងអ្នកសិក្សា។

## ៥.៣ សំណូមពរសម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ

- គួរធ្វើការវាយតម្លៃលើសមត្ថភាពក្នុងការរៀបចំផែនការអប់រំនៅការិយាល័យក្រុង ស្រុក ខណ្ឌ
- សិក្សាពីប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំក្នុងការលើកកម្ពស់ការអប់រំនៅក្នុងក្រុង ស្រុក ខណ្ឌ
- សិក្សាស៊ីជម្រៅអំពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំក្នុងបរិបទនៃការធ្វើវិមជ្ឈការអប់រំ

# ឯកសារយោង


Onn, S.,&Hyojin, K. (2019). Challenges to Provincial Education Strategic Plan Preparation in Cambodia. Cambodia Education Review, 3(1), 98-114.

MoEYs. (2020). Guideline on Education Strategic Plan Formulation for District Office of Education, Youth and Sport 2019-2023 D-ESP. Ministry of Education, Youth and Sport.

MoEYs. (2019). Education Strategic Plan 2019-2023 ESP. Ministry of Education, Youth and Sport.

MoEYs. (2020). Report of Monitoring on Progress and Challenges of Education Strategic Plan Formulation Process of District Office of Education, Youth and Sport. Department of Planning: Ministry of Education, Youth and Sport.

Simon P. Albon, Isabeau Iqbal, and Marion L. Pearson. (2016) Strategic Planning in an Educational Development Centre: Motivation, Management, and Messiness. Strategic Planning in an Educational Development Centre, IX, .210.

IIEP. (2010). Educational Planning for development: Approaches and Challenges. Paris: IIEP-UNESCO.

Anton De Grauwe, IIEP. (2009). Without Capacity There is no Development. Paris: IIEP-UNESCO.

IIEP. (2015). Guidelines for Education Sector Plan Preparation. Paris: IIEP-UNESCO.

G. C. b CHANG. (2008). Strategic Planning in Education: Some Concepts and Methods. Paris: IIEP.

NP2-SNDD. (2021). National Program on Sub-National Democratic Development Phase 2 (2021-2030). Phnom Penh: Royal Government of Cambodia.

NSDP. (2019). National Strategic Development Plan 2019-2023. Phnom Penh: Royal Government of Cambodia.

MoEYs. (2020-2024). Capacity Development Master Plan 2020-2024. Ministry of Education, Youth and Sport.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១៖ សំណួរសម្ភាសន៍

### សំណួរសម្ភាសន៍ស្តីពី
### ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣
### របស់ការិយាល័យអប់រំ យុវជន និងកីឡា
### (ករណីសិក្សានៅក្រុងបាត់ដំបង និងក្រុងសំរោង)

**ការណែនាំ៖** សំណួរនេះប្រើសម្រាប់សម្ភាសន៍អ្នកទទួលបន្ទុកក្នុងរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅក្រសួងអប់រំ យុវជន និងកីឡា។

**I. ព័ត៌មានទូទៅរបស់អ្នកចូលរួម**

១. ឈ្មោះ៖...............................................ភេទ៖.................អាយុ៖................................

២. តួនាទី៖...........................................................................................................

៣. កម្រិតវប្បធម៌៖...................................................................................................

៤. អង្គភាព៖............................................................រយៈពេលបម្រើការងារ៖....................

